ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សមាគមបុគ្គលិកសិក្សាខ្មែរ

* ចំណងមិត្តភាពនិងការឧបត្ថម្ភគ្នាទៅវិញទៅមក
* ការពង្រឹងនិងពង្រីកចំណេះដឹង និង វិជ្ជាជីវៈ
* ការការពារផលប្រយោជន៍គ្នាទាំងផ្លូវចិត្ត - សំភារៈ

៣៧

# ទស្សនាវដ្តី គ្រូបង្រៀន




ខែ តុលា_វិច្ឆិកា_ធ្នូ ឆ្នាំ ២០០៨
ខែ មករា_កុម្ភៈ_មីនា ឆ្នាំ ២០០៩

ផ្សាយចេញរាល់ត្រីមាស ពីទីចាត់ការសមាគមបុគ្គលិកសិក្សាខ្មែរ
១២៨B មហាវិថីព្រះនរោត្តម (ភ្នំពេញ)

# មាតិកា

| | | |
|---|---|---|
| **គណៈកម្មការរៀបរៀង និងនិពន្ធ** | | |
| - លោកស្រី | ប៊ុន | សារ៉ន |
| - លោកស្រី | ហួរ | ស៊ីរ |
| - លោកស្រី | ប៉ែន | ណារុល |
| - លោក | ថោង | បូរ៉ាន់ |
| - លោក ស្រី | គុយ | ផល្លា |
| - លោកស្រី | ប្រាក់ | សូលីដា |
| - លោក | ជន | ឈាងលី |
| - លោក | កៅ | ជឿន |
| - លោក | ស្វាយ | ទិត្យ |
| - លោក | ជុំ | ហ៊ុន |
| - លោក | ប៉ែន | សារុន |
| - សមាជិក_សមាជិកាស.ប.ស.ខ | | |
| **គណៈកម្មការត្រួតពិនិត្យ** | | |
| - លោក | យស់ | អ៊ាង |
| - លោក | សួង | សារុណ |
| - លោក | ស៊ុង | វ៉ាន់ថន |
| - លោកបណ្ឌិត | អ៊ឹម | គុច |
| - លោក | ស៊ិន | ស៊ីម |
| - លោក | អ៊ិន | ថេរ |
| - លោកស្រី | ទន់ | សាអ៊ីម |
| **ចិចិត្រករ** | | |
| លោក | ចាន់ | ត្រា |
| **ការិកុំព្យូទ័រ** | | |
| កញ្ញា | ម៉ៃ | សូនី |
| **គ្របខាងក្រៅ** | | |
| - ពីមុខ: សាលាបឋមសិក្សា អូរពក ខេត្តឧត្តរមានជ័យ | | |
| - ពីក្រោយ: សាលាចារាំង _ ខ្មែរ | | |


| ល.រ | ចំណងជើងអត្ថបទ | ទំព័រ |
|---|---|---|
| ១ | វិចារណកថា | ១ |
| | **រាជកិច្ច** | |
| ២ | ច្បាប់ស្តីអំពីការអប់រំ | ២ |
| | **ចប្បធម៌ទូទៅ** | |
| ៣ | ប្រពៃណីប្រើប្រាស់ទៀនក្នុងសង្គមខ្មែរ (តចប់) | ៥ |
| ៤ | សកម្មភាពពុទ្ធសាសនាកាត់បន្ថយភាពក្រីក្រ | ៨ |
| ៥ | ជីវិត និងសេចក្តីស្លាប់ (តចប់) | ១០ |
| | **ចិត្តវិទ្យា-អប់រំ** | |
| ៦ | យល់ដឹងអំពីទារកភាព (តចប់) | ១៣ |
| ៧ | វិបត្តិជំលោក និងផលប៉ះពាល់របស់វាទៅលើការរៀនសូត្ររបស់សិស្ស | ១៦ |
| | **វិទ្យាសាស្ត្រ និងព័ត៌មានវិទ្យា** | |
| ៨ | ការអភិវឌ្ឍជំនាញវិស្វកម្ម | ១៩ |
| | **ការអប់រំ និងគរុកោសល្យ** | |
| ៩ | ការតុបតែងបន្ទប់រៀន | ២២ |
| ១០ | ការដឹកនាំ និងការគ្រប់គ្រង | ២៥ |
| ១១ | មូលភេទ អ-អិ (ត) | ២៩ |
| ១២ | គណិតវិទ្យា : ការដោះស្រាយចំណោទ (ត) | ៣២ |
| ១៣ | ល្បែងប្រៃសារ | ៣៤ |
| ១៤ | គំនូរ : វិធីបង្រៀនគំនូរ (ត) | ៣៥ |
| | **នាទីកំណាព្យ និង កំសាន្ត** | |
| ១៥ | ជីវភាពថ្មីលើដីពាមជាំង | ៣៧ |
| ១៦ | ផលប៉ះពាល់នៃឥទ្ធិពលគ្រឿងញៀន | ៣៨ |
| ១៧ | ធមិជាស់តឿនកូនចៅ | ៤០ |
| | **វេទិកាស្ត្រី** | |
| ១៨ | រឿងព្រេងភ្នំបាណន់ | ៤១ |
| ១៩ | វេទិកាស្ត្រី : ប្រវត្តិកប៉ាល់ថ្ម | ៤៣ |
| | **ព័ត៌មាន** | |
| ២០ | តើលោកគ្រូ អ្នកគ្រូ ដឹងឬទេ... | ៤៥ |
| ២១ | សង្ខេបរបាយការណ៍សាលារៀនតាមឃុំ សង្កាត់ ឆ្នាំសិក្សា ២០០៧-០៨ | ៤៦ |
| ២២ | ស្ថិតិសពខែកក្កដា-សីហា-កញ្ញា ឆ្នាំ២០០៨ | ៤៧ |



**ទូរស័ព្ទផ្ទះគ្រូបង្រៀន**

ភ្នំពេញ : ០១២ ៨៩៧ ១៧៧, កំពត : ០១២ ៨៥៦ ៧២២, ព្រះសីហនុ : ០១២ ៦៥៩ ៥៦០

សៀមរាប : ០១២ ៦៧៥ ៦៤០ តាកែវ : ០១២ ១ ៧០៣ ០២៧ កំពង់ចាម : ០១១ ៧៤២ ២២៤ រតនគិរី : ០១២ ៩៨២ ៨៦០

# វិចារណកថា

ក្នុងឱកាសដ៏ប្រពៃថ្លៃថ្លានៃ "ទិវាគ្រូបង្រៀន ៥តុលា" សមាគមបុគ្គលិកសិក្សាខ្មែរ ស.ប.ស.ខ. ដែលមានសមាជិក សមាជិកាជាង ៩ ម៉ឺននាក់ សូមចូលរួមអបអរសាទរជាមួយសង្គមជាតិទាំងមូល សំដៅរំលឹកពីប្រពៃណីដ៏ល្អផូរផង់ពាក់ព័ន្ធនឹងវប្បធម៌គោរពស្រឡាញ់ដឹងគុណគ្រូបង្រៀន ដែលប្រជាជនខ្មែរទាំងមូលបានចាត់ទុកដោយមានទម្ងន់ផ្នែកសីលធម៌ថា "លោកគ្រូ អ្នកគ្រូ ជាបិតា មាតាទី២ នៃបុត្រធីតារបស់ខ្លួន" និងលើកកំពស់ឡើងវិញនូវសេចក្តីថ្លៃថ្នូររបស់យើងទាំងអស់គ្នា ក្នុងនាមជាជនជាតិមួយដែលមានប្រវត្តិសាស្ត្រយូរអង្វែង និងអារ្យធម៌ដ៏រុងរឿង។

ដោយឡែកសម្រាប់កម្ពុជា រាជរដ្ឋាភិបាល ក្រោមការដឹកនាំរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានផ្តួចផ្តើមគំនិតបង្កើតទិវានេះ តាំងពីឆ្នាំ ១៩៩៧ ដោយជ្រើសរើសយកថ្ងៃទី០៥ តុលា នៃឆ្នាំនីមួយៗ ស្របតាមការប្រកាសរបស់ UNESCO នាឆ្នាំ១៩៦៦ថា ០៥ តុលា ជាទិវាគ្រូបង្រៀនពិភពលោក។ បច្ចុប្បន្ននេះមានប្រទេសប្រមាណ ២០០ បានប្រារព្ធទិវាគ្រូបង្រៀន ៥ តុលា ក្នុងបរិយាកាសយ៉ាងសប្បាយរីករាយ។

ការយកចិត្តទុកដាក់ខាងលើ ពិតជាត្រឹមត្រូវ ព្រោះពីមួយថ្ងៃទៅមួយថ្ងៃ ពីមួយឆ្នាំទៅមួយឆ្នាំ គ្រូបង្រៀនក្នុងភារកិច្ចជាអ្នកអប់រំបណ្តុះបណ្តាល ជាគរុកោសល្យវិទូបានខិតខំដោយអំណត់ព្យាយាម ដោយសេចក្តីស្រឡាញ់ ដើម្បីផ្ទេរចំណេះដឹងចំណេះធ្វើ ដែលជាតម្លៃនៃវិទ្យាសាស្ត្របច្ចេកទេស អាកប្បកិរិយា ឥរិយាបថ សីលធម៌ គុណធម៌ ចំពោះកុមារា កុមារី សិស្ស និស្សិតនៅគ្រប់ទិសទី ក្នុងគោលការណ៍ដ៏ពិសិដ្ឋ គឺប្រែក្លាយពួកគេជាពលរដ្ឋល្អ មានសមត្ថភាពរួមចំណែកក្នុងការការពារ និងការកសាងជាតិប្រកបដោយប្រសិទ្ធភាព។ បើគ្មានវិភាគទានរបស់គ្រូបង្រៀន នោះការប្រឹងប្រែងដទៃទៀតនឹងពុំអាចសំរេចដោយជោគជ័យទាំងស្រុងបានឡើយ។ ក្នុងទស្សនៈនេះហើយទើបសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាបានឧទ្ទិសឱ្យ "ទិវាគ្រូបង្រៀន ០៥ តុលា" ក្លាយជាទិវាដឹងគុណគ្រូជាអមតៈ។

សមាគមបុគ្គលិកសិក្សាខ្មែរ ស.ប.ស.ខ. សូមគាំទ្រ និងរួមចំណែកជាមួយសង្គមជាតិទាំងមូល ដើម្បីអនុវត្តទស្សនៈនេះក្នុងស្មារតីរក្សានូវទម្លាប់គោរពស្រឡាញ់ដឹងគុណគ្រូឱ្យស្ថិតក្នុងបេះដូងរបស់សិស្ស និស្សិត និងមនុស្សគ្រប់ៗរូបជានិច្ចនិរន្តន៍៕

**គណៈកម្មាធិការកណ្តាល**

# ព្រះរាជក្រម

នស/រកម/១២០៧/០៣២

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការអប់រំ ដែលរដ្ឋសភា បានអនុម័តកាលពីថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបាន យល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាល ពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី៤ នីតិកាល ទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :



## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.- គោលដៅ**

ច្បាប់នេះមានគោលដៅកំណត់អំពីវិធាន និងលក្ខខណ្ឌតម្រូវថ្នាក់ជាតិ សម្រាប់កសាងប្រព័ន្ធអប់រំមួយពេញលេញ និងឯកភាព ដែលធានានូវគោលការណ៍សេរីភាពខាងសិក្សា-ធិការ ស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២.- គោលបំណង**

ច្បាប់នេះមានគោលបំណងអភិវឌ្ឍធនធានមនុស្ស ដោយផ្តល់ការអប់រំពេញមួយជីវិតសម្រាប់ទាំងអស់គ្នា ដើម្បីឱ្យអ្នកសិក្សាទទួលបាននូវចំណេះដឹង ជំនាញ សមត្ថភាព សេចក្តីថ្លៃថ្នូរ អាកប្បកិរិយាប្រកបដោយសីលធម៌ សំដៅជំរុញឱ្យអ្នកសិក្សាស្គាល់ ស្រឡាញ់ រួមចំណែកការពារអត្តសញ្ញាណជាតិ វប្បធម៌ជាតិ និងភាសាជាតិ ។

**មាត្រា ៣.- វិសាលភាពអនុវត្តន៍**

ច្បាប់នេះមានវិសាលភាពលើគ្រប់កម្មវិធីអប់រំ សិក្សាស្រាវជ្រាវ អប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈគ្រប់ប្រភេទ គ្រប់កម្រិតភូមិសិក្សាសាធារណៈ និងឯកជននៃប្រព័ន្ធអប់រំ ទោះជាកម្មវិធីអប់រំនោះ ធ្វើឡើងនៅក្នុងស្ថាប័នអប់រំ ឬ ដោយបុគ្គលិកអប់រំព្រមទាំងគ្របដណ្តប់លើរដ្ឋបាលកិច្ចនិងការគ្រប់គ្រងការអប់រំគ្រប់កម្រិត លើកលែងតែការអប់រំអំពីគម្ពីរសាសនា ការអប់រំខាងបច្ចេកទេស យុទ្ធសាស្ត្រយោធា និងសន្តិសុខ ការអប់រំខាងផ្នែកគ្រប់គ្រងរដ្ឋបាលដែនដី ការអប់រំដែលផ្តល់ដោយសាលាភូមិន្ទរដ្ឋបាល និងការអប់រំបច្ចេកទេស និងវិជ្ជាជីវៈតុលាការដែលផ្តល់ដោយស្ថាប័នបណ្តុះបណ្តាលឯកទេសវិជ្ជាជីវៈច្បាប់ និងតុលាការ ។

ច្បាប់នេះអនុវត្តផងដែរលើបុគ្គល និងអ្នកពាក់ព័ន្ធផ្សេងៗទៀត ដូចជាកុមារដែលស្ថិតក្នុងអាយុត្រូវចូលសិក្សា អ្នកសិក្សា មាតាបិតា ឬ អ្នកអាណាព្យាបាល ក្រុម ឬ ក្លឹបអ្នកសិក្សា និងបុគ្គលិកអប់រំ ព្រមទាំងអ្នកកាន់អាជ្ញាប័ណ្ណអប់រំ និងសិទ្ធិវន្តនៃអាជ្ញាប័ណ្ណអប់រំ លើកលែងតែអ្នកដែលពាក់ព័ន្ធក្នុងការអប់រំ និង ប្រតិបត្តិខាងសាសនា បច្ចេកទេស យុទ្ធសាស្ត្រយោធា និងសន្តិសុខផ្នែកគ្រប់គ្រងរដ្ឋបាលដែនដី ផ្នែកភូមិន្ទរដ្ឋបាល និងផ្នែកវិជ្ជាជីវៈតុលាការ ។

### មាត្រា ៤.- និយមន័យការអប់រំ និងពាក្យសំខាន់ៗ

ការអប់រំក្នុងច្បាប់នេះ សំដៅដល់កិច្ចដំណើរការអភិវឌ្ឍការសិក្សា ឬ ការបណ្តុះបណ្តាលកាយសម្បទា ស្មារតី បញ្ញា និងសីលធម៌ តាមរយៈគ្រប់រូបភាពអប់រំ ដែលធ្វើឱ្យអ្នកសិក្សាទទួលបានសំណុំចំណេះដឹង ជំនាញ សមត្ថភាព និងតម្លៃ ដើម្បីឱ្យក្លាយខ្លួនជាបុគ្គលល្អដែលមានប្រយោជន៍សម្រាប់ខ្លួនឯង គ្រួសារ សហគមន៍ ប្រទេសជាតិ និងពិភពលោក ។

វាក្យស័ព្ទសំខាន់ៗដែលប្រើក្នុងច្បាប់នេះ មានភ្ជាប់ជាឧបសម្ព័ន្ធនៃច្បាប់នេះ ។

## ជំពូកទី ២
## ឧត្តមក្រុមប្រឹក្សាជាតិអប់រំ

### មាត្រា ៥.- ការបង្កើតឧត្តមក្រុមប្រឹក្សាជាតិអប់រំ

ត្រូវបង្កើតឧត្តមក្រុមប្រឹក្សាជាតិអប់រំ ដែលមានភារកិច្ច :

-លើកសំណើគោលនយោបាយអប់រំ និងយុទ្ធសាស្ត្ររយៈពេលវែងសំដៅឆ្លើយតបទៅនឹងសំណូមពរអភិវឌ្ឍសង្គម សេដ្ឋកិច្ចរបស់ប្រទេសជាតិជូនរាជរដ្ឋាភិបាល

-វាយតម្លៃការងារ ដែលពាក់ព័ន្ធនឹងវិស័យអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈតាមកាលកំណត់ជូនរាជរដ្ឋាភិបាល ។

-កៀរគរគ្រប់ធនធាន ដើម្បីបម្រើបុព្វហេតុអប់រំ

### មាត្រា ៦.- សមាសភាព និង ការរៀបចំ និងការប្រព្រឹត្តទៅ

ឧត្តមក្រុមប្រឹក្សាជាតិអប់រំ ស្ថិតក្រោមការដឹកនាំរបស់នាយករដ្ឋមន្ត្រី ។

សមាសភាពរបស់ឧត្តមក្រុមប្រឹក្សាជាតិអប់រំត្រូវតែងតាំងក្នុងចំណោមឥស្សរជនដែលមានបទពិសោធន៍ខាងអប់រំ នយោបាយ សេដ្ឋកិច្ច វិទ្យាសាស្ត្រ បច្ចេកទេស វប្បធម៌ ។

សមាសភាពរបស់ឧត្តមក្រុមប្រឹក្សាជាតិអប់រំត្រូវតែងតាំងដោយព្រះរាជក្រឹត្យ ។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់ឧត្តមក្រុមប្រឹក្សាជាតិអប់រំ ត្រូវកំណត់ដោយអនុ-

ឧត្តមក្រុមប្រឹក្សាជាតិអប់រំមានក្រសួងទទួលបន្ទុកវិស័យអប់រំ និងស្ថាប័នទទួលស្គាល់ឧត្តមក្រុមប្រឹក្សាជាលេខាធិការ ។



5h8...

(នៅមានត)

# វប្បធម៌ខ្មែរ



## ប្រពៃណីប្រើប្រាស់ទៀនក្នុងសង្គមខ្មែរ (តចប់)

### ៧-ទៀនជើង ត្បូង

ទៀននេះមានរូបរាងដូចទៀនស្នែងក្របីដែរ។ ប៉ុន្តែវិធីប្រើប្រាស់គឺខុសប្លែកគ្នា។ គេកត់សំគាល់ឃើញថា ទៀននេះប្រើតែក្នុងពិធី ២ យ៉ាងគត់ ពោលគឺប្រើសម្រាប់ពេលកើត និងពេលស្លាប់ប៉ុណ្ណោះ។

ពេលកើត គេយកទៀននេះដោតចំកណ្តាលអង្ករ១ចាន ដែលមានរៀបកាក់ ៤ តំកល់លើស្រូវ១កញ្ជើ ដាក់លើក្បាលដំណេកទារក "ក្បាលហៅត្បូងក៏បាន" ជាដង្វាយដល់ឆ្មបដែលមានគុណនៅពេលបង្កើត។

ពេលមានមនុស្សស្លាប់ គេក៏រៀបដូចគ្នានេះដែរ។ ប៉ុន្តែគេយករៀបមកដាក់ខាង "ចុងជើងបុគ្គលវិញ" ទុកជាដង្វាយដល់អាចារ្យដែលជាអ្នកមានគុណខាងផ្លូវធម៌នៅពេលស្លាប់។

### ៨-ទៀនត្រែង

គេកំណត់ឱ្យឈ្មោះថា ទៀនត្រែង ពីព្រោះទៀននេះមានលំនាំរូបរាងដូចដើមត្រែង គឺវែង១ស្មើនឹងកម្ពស់មនុស្សទំហំប៉ុន១ម្រាមដៃ។ ទៀននេះគេមិនបានកំណត់ទម្ងន់ទៀងទាត់ទេ។ គេប្រើវាក្នុងពិធីល្បៀងអារក្សតាមទំនៀមទម្លាប់ដូនតាគេ។ បើកាលណាមានមនុស្សឈឺ ហើយដូនតាតម្រូវឱ្យល្បៀងអារក្ស ហើយគេបង្គាប់ឱ្យល្បៀងអារក្សរៀបរណ្តាប់ បើត្រូវត្រង់ឱ្យមានទៀននេះប្រើប្រាស់ គេលុញទៀននេះឱ្យបានប្រវែងស្មើនឹងកំពស់មនុស្សឈឺ ទើបហៅថា ទៀនត្រែង។ តែបច្ចុប្បន្ននេះគេបានសន្មតយកទៀនខ្លី១មកធ្វើជានិមិត្តរូបទៀនត្រែងបានដែរ។

### ៩-ទៀនបេះបក

ទៀននេះប្រើប្រាស់ក្នុងពិធីសុំចងស្ពានមេត្រីស្ដីដណ្ដឹងកូនក្រមុំ និងពិធីបង្កក់ឆ្មបពេលកូនទើបនឹងកើត។ គេធ្វើទៀននេះដូចទៀនវាយធម្មតា តែមានប្រវែងប្រមាណ១ម៉ែត្រ រួចគេពត់ទៀននោះឱ្យទៅជារាងរង្វង់តូចខ្មៅ ហើយពត់ចុងបន្តិចភ្ជាប់ទៅនឹងមាត់ផង់រង។ វេលាមេបានិយាយពីការងារ គេអុជទៀននោះឡើង...។ បើមេបានិយាយមិនទាន់ចប់សព្វគ្រប់ទេ ហើយទៀននោះឆេះខ្លីមកក្រោម គេបេះទៀនចេញពីមាត់ផង់រង លាតចុងឱ្យវែងបន្តិចទៅទៀត។ ខណៈដែលគេបេះបិទជាថ្មីនោះ គេមិនពន្លត់ទៀនទេ គឺទុកឱ្យឆេះដដែល គ្រាន់តែលាតឱ្យវែងតែប៉ុណ្ណោះ។ គេបេះបិទដូចនេះជាប្រចាំ

រហូតទាល់តែមេបាទិយាយការងារចប់។

ចំពោះពិធីបង្កក់ឆ្អបវិញ តេប្រើទៀនទេះដែរ ប៉ុន្តែខុសប្លែកត្រង់គេយកទៀនរាយ៣គូ មកវេញឱ្យបានជាទៀន៣ ហើយបិទនៅលើពពិលទាំង៣ អុជបង្វិលប្រទក្សិណជុំវិញទារក១៩ជុំ គឺការហៅព្រលឹងទាំង១៩ ឱ្យចូលមកសណ្ឋិតលើទារកនោះ ព្រោះថាទារកដែលកើតមកថ្មីៗមានការតក់ស្លុត និងភិតភ័យ។ ពេលបញ្ចប់ពិធីបង្វិលពពិលអាចារ្យបង្គាប់ឱ្យពន្លត់ទៀនរួចបេះប្រផេះទៀនបិទនឹងត្របកភ្នែកទារក ដើម្បីជានិមិត្តរូបឱ្យចៀសផុតពីភយន្តរាយ។ ដូចនេះ ទើបគេសន្មត់ឱ្យឈ្មោះទៀនបែបនេះថា ជា "ទៀនបេះបក" ផងដែរ ព្រោះគេបេះប្រផេះ ទៀនបកបិទនៅលើភ្នែកទារក។

## ១០-ទៀនប្រាំ

គេឱ្យឈ្មោះទៀននេះសំរបទៅនឹងចំនួនទៀនដែលគេប្រារព្ធប្រើជាវត្ថុសក្ការបូជាក្នុងពិធីសាសនា។

ចំនួន ៥ នេះ មានភាពស្របគ្នាទៅនឹងទិសធំៗទាំងបួនបូកនឹងមជ្ឈមណ្ឌល គឺមជ្ឈមណ្ឌលកណ្ដាលនៃទ្វីប។

ចំនួន ៥ នេះ មានភាពស្របគ្នាទៅនឹងចំនួនព្រះពុទ្ធទាំង ៥ ព្រះអង្គក្នុងអាយុកល្បនៃផែនដីយើងនេះដែលត្រាស់ហើយបាន ៤អង្គ និង១ព្រះអង្គទៀតពុំទាន់បានត្រាស់។ ទៀននេះមានទំហំប៉ុនកូនដៃ ប្រវែង១ចំអាម គេប្រើប្រាស់សម្រាប់អុជឧទ្ទិសជាដង្វាយសម្រាប់ថ្វាយដល់ពពួកទេវតា។

## ១១-ទៀនរាយ

ទៀននេះទំហំតូចៗ វាគឺជាទៀនដែលគេអុជជាធម្មតា។ គេហៅម្យ៉ាងទៀតថា "ទៀនបរិវា" ក៏បាន ព្រោះវាត្រូវប្រើរែបជាមួយនឹងទៀនដែលមានឈ្មោះខាងលើមួយចំនួនក៏បាន។ គេប្រើប្រាស់វាតែឯកឯងក៏បាន។ ទៀននេះឥតមានកំណត់ទម្ងន់ ឬចំនួនសរសៃអំបោះនៅសម្រាប់ធ្វើប្រឆេះទេ។ ឈ្មោះទៀននេះគឺសំដៅតែទៅលើការប្រើប្រាស់តែប៉ុណ្ណោះ។



១.ទៀនរាយ ២.ទៀនវស្សា ៣.ទៀនព្រែង

## ១២-ទៀនពេលា

ទៀននេះគេអាចហៅម្យ៉ាងទៀតថា "ទៀនកំណត់" គេប្រើជាពិសេសក្នុងពិធីរៀបមង្គលការ។ កាលពីបុរាណ មុនថ្ងៃកំណត់ពិធី គេនិយមឱ្យសាមីខ្លួនខាងប្រុសដើរស្វែងរកសំបុកឃ្មុំក្នុងព្រៃជ្រៅ ដើម្បីយកក្រមួនមកធ្វើជាទៀនពេលាឱ្យបាន១គូ តំណាងគូស្រករថ្មី។ គេធ្វើទៀននេះដោយកំណត់ទម្ងន់ គឺទៀន១ទម្ងន់១តម្លឹងក្រមួនសុទ្ធកម្ពស់គេកំណត់ខាងប្រុសផ្សេង កូនស្រីផ្សេង គឺប្រុសគេកំណត់ឱ្យយក១ហត្ថកូនប្រុស ចំណែកកូនស្រីឱ្យយក១ហត្ថកូនស្រី។ អាចារ្យខ្លះកំណត់ទៀនពេលានេះ គឺវង្វាស់១ជុំក្បាលនៃបុរសស្ត្រីដែលទទួលពេលា។ ឯចំនួនសរសៃអំបោះធ្វើប្រឆេះ គឺកំណត់ទៅតាមរាសីនៃ

បុរសស្ត្រីជាសាមីខ្លួន ព្រោះថាទៀនពេលានេះជាមូលហេតុធ្វើឱ្យកើតមង្គលផ្សេងៗ។ ក្នុងពិធីរៀបមង្គលការ អាចារ្យយកទៀនពេលានេះទៅបិទភ្ជាប់នឹងផ្តិលទឹកសម្រាប់បុរស១ ស្រី១ ដោយមានដាក់សរសៃអំបោះសម្រាប់ចងដៃគូស្វាមីភរិយាថ្មីអុជនៅពេលផ្ទឹម។ ម្យ៉ាងទៀតក្នុងតំបន់ខ្លះគេសង្កេតឃើញមានការប្រើប្រាស់ទៀនពេលានេះសម្រាប់អ្នកចេញបួសផងដែរ។



៤_ទៀនបង្វិលពពិល



៥_ទៀនស្នែងក្របី



៦_ទៀនបេះបក



៧_ទៀនពេលា

## <u>សេចក្តីសន្និដ្ឋាន</u>

សព្វថ្ងៃនេះ ប្រពៃណីនៃការប្រើប្រាស់ទៀនដ៏សំបូរបែបតាមពិធីបុណ្យផ្សេងៗក្នុងសហគមន៍ខ្មែរបានចុះថយឥទ្ធិពលបន្តិចម្តងៗគួរឱ្យស្តាយស្រណោះ ព្រោះប្រពៃណី និងទំនៀមទម្លាប់នេះវាបានឆ្លុះបញ្ចាំងឱ្យឃើញនូវតម្លៃនៃវប្បធម៌អរិយធម៌ខ្មែរដែលមានអាយុកាលចំណាស់ជាងគេនៅឧបទ្វីបឥណ្ឌូចិន។

**ឯកសារពិគ្រោះ**


១-វចនានុក្រមខ្មែរភាគទី១ និងទី២: ពុទ្ធសាសនបណ្ឌិត្យ

២-តន្ត្រី និងជីវិតខ្មែរ : អ្នកស្រីកែវ ណារុំ

៣-ប្រលឹងមាតាធិបតេយ្យក្នុងសង្គមខ្មែរ : ឯកឧត្តម ងួន ញ៉ិល

៤-ពិធីក្នុងគ្រួសារខ្មែរ : ពុទ្ធសាសនបណ្ឌិត្យ

៥-អរិយធម៌ : នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ

៦-Notes sur les particularités du culte chez les Cambodgiens : Eveline Maspéro

៧-Les offrandes au Cambodge : Institut Bouddhique, commission mœurs et coutumes

៨-លំអានទំនៀមខ្មែរបុរាណ : លោក ញាណ ភឿន និងលោកម៉ម ផៃ



លោក **ចាប សំណាង**

**មន្ត្រីអប់រំសាលាគរុ.ខេត្តបាត់ដំបង (ចូលនិវត្តន៍)**

# សកម្មភាពព្រះពុទ្ធសាសនាកាត់បន្ថយភាពក្រីក្រ

## ១-ព្រះសង្ឃ និងការអប់រំ

### ១.១-ធនធានព្រះសង្ឃ

តាំងពីបុរាណកាលរហូតដល់បច្ចុប្បន្ន ប្រទេសកម្ពុជាជាប្រទេសមួយដែលប្រជាពលរដ្ឋភាគច្រើនមានជំនឿជឿជាក់លើព្រះពុទ្ធសាសនា ព្រោះជាសាសនាមានហេតុផលច្បាស់លាស់។ ប្រជាពលរដ្ឋខ្មែរមួយចំនួនធំ ពិសេសនៅតាមទីជនបទ ឬប្រជាពលរដ្ឋក្រីក្របានបញ្ជូនកុលបុត្រឱ្យមកស្នាក់នៅក្នុងវត្តអារាម ដើម្បីសិក្សារៀនសូត្រព្រះធម៌វិន័យក្នុងសំណាក់ព្រះគ្រូចៅអធិការ គ្រូសូត្រស្តាំ-ឆ្វេង ឬក្នុងសំណាក់គ្រូអាចារ្យ ដើម្បីចូលបួសជាភិក្ខុ ឬជាសាមណេរក្នុងព្រះពុទ្ធសាសនា ដោយពួកគេយល់ថា ការបំបួសកូនក្នុងព្រះពុទ្ធសាសនាបានបុណ្យកុសលច្រើន អាចនឹងជួយសណ្តោងយឹតយោងពួកគេ (មាតាបិតា) ឱ្យរួចផុតពីសេចក្តីទុក្ខលំបាកទាំងឡាយបាន ម្យ៉ាងទៀតខ្មែរយើងតែងមានជំនឿថា ការចូលបួសក្នុងព្រះពុទ្ធសាសនា គឺសងគុណមាតាបិតាបាន។

កុលបុត្រខ្មែរដែលបួសក្នុងព្រះពុទ្ធសាសនាមានចំនួនច្រើនរហូតដល់ ៥៧ ៣៥០អង្គ ក្នុងនោះគណៈធម្មយុត្តិកនិកាយមានចំនួន ១ ២២០អង្គ[១]។ ដោយសារចំនួនព្រះសង្ឃដ៏ច្រើនស្ថិតក្នុងវ័យសិក្សា វ័យកម្លាំង ពលកម្ម និងច្រើនចេញពីត្រកូលអ្នកក្រីក្រនៅតាមជនបទ ដូច្នេះហើយទើបមានទស្សនៈមួយបានប្រកាន់ថា បុរសជាសសរទ្រូងនៃប្រទេសជាតិ និងជាកម្លាំងមាំក្នុងគ្រួសារ កាលបុរសចេញបួសច្រើនបានធ្វើឱ្យប្រទេសខ្មែរយើងក្រីក្រ ប្រជាជនតាមជនបទសម្បូរអ្នកក្រីក្រ។ តើរឿងហ្នឹងពិតទេ? ប្រទេសខ្មែរក្រ ឬប្រជាពលរដ្ឋក្រីក្រ ព្រោះបុរសចេញបួសច្រើន ឬដោយសារកាន់ស៊ប់នឹងព្រះពុទ្ធសាសនាមែនទេ?

បើតាមគោលការណ៍គ្រឹះជាយុទ្ធសាស្ត្ររបស់ព្រះពុទ្ធសាសនា គួរតែនិយាយថា ប្រទេសខ្មែរក្រ ឬថាប្រជាពលរដ្ឋក្រីក្រមកពីមិនធ្វើតាម មិនប្រតិបត្តិតាមព្រះពុទ្ធសាសនាវិញទើបត្រឹមត្រូវ។ ការពិតរឿងបុរសចេញបួសច្រើននេះ គឺជួយក្រុមគ្រួសារ ក៏ដូចជារាជរដ្ឋាភិបាលជាច្រើនដូចជាជួយ :

- កាត់បន្ថយកំណើនប្រជាជន
- កាត់បន្ថយភាពឥតការងារធ្វើ
- កាត់បន្ថយអំពើហិង្សាក្នុងគ្រួសារ និងសង្គម
- កាត់បន្ថយភាពរាលដាលនៃជំងឺឆ្លងមួយចំនួន ដូចជាជំងឺអេដស៍ជាដើម
- ធ្វើឱ្យសង្គមមានសុខសន្តិភាព មិនមានភាពវឹកវរ ដោយសារយុវជនទាំងនោះ (ព្រះសង្ឃ) រួចផុតពីអំពើអបាយមុខផ្សេងៗមានគ្រឿងញៀន ស្រីស្រា ល្បែង ឬបងតូចបងធំ។ល។

### ១.២-ការអប់រំព្រះសង្ឃ

(១) ស្ថិតិព្រះសង្ឃឆ្នាំ២០០៧ (សុន្ទរកថារបស់ឯកឧត្តម ឃុន ហាំង រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា ក្នុងឱកាសអនុសំវច្ឆរៈមន្ត្រីសង្ឃលើកទី១៦)

ក្រោយពេលកុលបុត្រទាំងឡាយបានបួសហើយ មិនមែនរៀនសូត្រត្រឹមតែធម៌វិន័យសម្រាប់ប្រតិបត្តិក្នុងព្រះពុទ្ធសាសនាតែប៉ុណ្ណោះទេ គឺត្រូវសិក្សានូវចំណេះដឹងទូទៅដូចជា គណិតសាស្ត្រ អក្សរសាស្ត្រ វិទ្យាសាស្ត្រ ឯកទេសបច្ចេកទេស ជំនាញវិជ្ជាជីវៈផ្សេងៗ រួមទាំងភាសាជាតិ និងអន្តរជាតិផងដែរ ដើម្បីសម្របសម្រួលទៅតាមសម័យកាលសកលភាវូបនីយកម្ម។ ព្រះសង្ឃ គឺជាធនធានមនុស្សដ៏ពិសេសសម្រាប់ការអភិវឌ្ឍន៍សង្គម ដូច្នេះទើបក្រសួងធម្មការ និងសាសនាបានបង្កើននូវគុណភាពនៃការអប់រំព្រះសង្ឃតាមរយៈពុទ្ធិកសិក្សា និងសាលាធម្មវិន័យដោយមានសាលាពុទ្ធិកបឋមសិក្សាចំនួន ៥៤៩សាលា មានសមណសិស្សចំនួន ១២ ១៧៤អង្គ ពុទ្ធិកអនុវិទ្យាល័យ២៦សាលា មានសមណសិស្សចំនួន ៤ ០៣៧អង្គ ពុទ្ធិកវិទ្យាល័យ ១១សាលា មានសមណសិស្សចំនួន ១ ៨៩៣អង្គ និងពុទ្ធិកសាកលវិទ្យាល័យចំនួនពីរកន្លែងនៅរាជធានីភ្នំពេញ គឺពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ និងពុទ្ធិកសាកលវិទ្យាល័យព្រះសីហមុនីរាជា។ ចំណែកសាលាធម្មវិន័យ ៧២៦សាលា សមណសិស្សចំនួន ១៣ ៦១២អង្គ[(២)] ។

## ២-ព្រះសង្ឃ និងការអភិវឌ្ឍសង្គម

ថ្វីត្បិតបច្ចុប្បន្នប្រទេសកម្ពុជាយើងមានការអភិវឌ្ឍន៍គួរឱ្យចាប់អារម្មណ៍ ដោយមានការចូលរួមជួយជ្រោមជ្រែងពីអង្គការជាតិ និងអន្តរជាតិលើគ្រប់វិស័យយ៉ាងណាក៏ដោយ ក៏យើងសង្កេតឃើញព្រះសង្ឃខ្មែរបានចូលរួមយ៉ាងសំខាន់ក្នុងការអភិវឌ្ឍន៍ប្រទេសជាតិ ដោយព្រះអង្គបានបង្កើតជាអង្គការផ្សេងៗដូចជា អង្គការពុទ្ធមណ្ឌលសុខុមាលភាពកុមារ អង្គការក្ដីសង្ឃឹមនៃកុមារ និងអង្គការពុទ្ធសាសនា ដើម្បីការអភិវឌ្ឍន៍ជាដើម។ ក្រៅពីនេះព្រះអង្គក៏បានចូលរួមចំណែកយ៉ាងសកម្មជាមួយអង្គការ ស្ថាប័ននានា និងចូលរួមផ្ទាល់ក្នុងការជួយសង្គម ពិសេសក្មេងកំព្រា ជនអនាថា ជនក្រីក្រ និងជនងាយរងគ្រោះ។

ក្នុងទិសដៅកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍន៍ ព្រះសង្ឃបានចូលរួមចំណែកក្នុងសង្គមដូចជា :

### ២.១-ការអប់រំ

យើងបានដឹងមកហើយថា ការអប់រំគឺជាកត្តាសំខាន់បំផុតសម្រាប់មនុស្ស ឬសម្រាប់ការអភិវឌ្ឍន៍ប្រទេស បើគ្មានការអប់រំ គឺគ្មានការអភិវឌ្ឍន៍ គ្មានការអភិវឌ្ឍន៍នាំឱ្យប្រជាពលរដ្ឋក្រីក្រ ប្រជាពលរដ្ឋក្រីក្រនាំឱ្យមានភាពវឹកវរចលាចល ដោយចោរលួច ចោរប្លន់ សេពគ្រឿងញៀន រំលោភផ្លូវភេទ ប្រព្រឹត្តអំពើហិង្សាផ្សេងៗ...។

(នៅមានត)

**អនុបណ្ឌិត គួយ សួគាន**

(២) ស្ថិតិព្រះសង្ឃឆ្នាំ២០០៧ (សុន្ទរកថារបស់ឯកឧត្ដម ឃុន ហ៊ាង រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា ក្នុងឱកាសអនុសំវច្ឆរៈមន្ត្រីសង្ឃលើកទី១៦)

# ជីវិត និងសេចក្តីស្លាប់ (តចប់)

**<u>ក្រោយពេលស្លាប់</u>**

តើម្នាក់ៗទៅឯណា? ចាប់ជាតិថ្មីទៀតនៅភពណា? ក្រោយពីបានស្លាប់រួចរាល់ហើយនោះ?

គ្មានអ្នកណាបានដឹងទេ ពីព្រោះអ្នកដែលបានស្លាប់ទៅហើយនោះមិនបានវិលមកប្រាប់យើងដែលកំពុងរស់នេះថា គេទៅកាន់ភពណា ស្ថានណា ទីណា កើតនៅឯណានោះទេ?

សូមស្តាប់ការបកស្រាយតាមទស្សនៈផ្សេងៗដូចតទៅ :

**១_តាមពុទ្ធសាសនា**

ក-បើធ្វើអំពើល្អ => ក្រោយពេលស្លាប់ទៅ => ទៅសោយសុខនៅស្ថានសួគ៌ ឬទៅនិព្វាន ។

ខ-បើធ្វើអំពើអាក្រក់ => ទៅស្ថាននរក ។

យើងមិនបានដឹងស្ថានសួគ៌ ឬស្ថាននរកពិតនៅឯណា? សប្បាយ ឬមិនសប្បាយ? ជួបការលំបាក ឬមានទុក្ខវេទនាយ៉ាងណានោះទេ?

**២_តាមសាសនាផ្សេងៗទៀត**

គឺទៅចាប់ជាតិថ្មីទៀតទៅតាមបំណងរបស់អាទិទេព ឬតាមកំណត់របស់អាទិទេព : កើតជាមនុស្ស ឬជាសត្វ ឬជារុក្ខជាតិ? គឺគ្មានទរណាដឹងទេ! គឺគ្រាន់តែនាំគ្នាស្រមៃ ឬក៏ស្ថិតក្នុងសុបិនចំលែកតែប៉ុណ្ណោះ ។

ឥឡូវ សូមសាកល្បងគិតតាមបែបទស្សនវិជ្ជាដូចតទៅ :

<u>សំណួរ</u> : តើមានជាតិក្រោយដែរឬទេ? តើមានការចាប់ជាតិជាថ្មីទៀតដែរឬទេ ក្រោយការស្លាប់ហើយនោះ?

យើងសាកល្បងលើកយកតែចំលើយ ២ ប៉ុណ្ណោះដែលសំខាន់ :

១_គឺគ្មានទេ : ការបកស្រាយមានដូចខាងក្រោម :

ក_តាមទស្សនវិជ្ជាអត្ថិភាពនិយម (Existentialism) គឺគ្មានទេ! គ្មានជាតិមុន និងគ្មានជាតិក្រោយឯណានោះទេ គឺមានតែជាតិបច្ចុប្បន្ននេះតែមួយគត់ ។ ផុតពីជាតិនេះទៅ គឺចប់ៗៗៗ...ហើយ ។

ខ_ទ្រឹស្តីលោក Pasteur : លោកជាគីមីវិទូ និងជីវវិទូបារាំង ។ លោកបានបញ្ជាក់ថា ពុំមានកំណើតដោយឯកឯង នោះទេ ។ អ្វីៗគឺកើតឡើងពីមេកំណើត ឬហៅថា បុព្វបុរសរបស់វា ។

២_គឺមាន

**ក-ទស្សនៈពុទ្ធនិយម** : តាម "ទស្សនៈកម្មផល" ដែលទាក់ទងទៅនឹងការកើត និងស្លាប់នោះ គឺខន្ធ ៥ ដែលមាន រូបខន្ធ វេទនាខន្ធ សញ្ញាខន្ធ សង្ខារខន្ធ និងវិញ្ញាណខន្ធ ។

ធាតុទាំង ៥ នេះជួបប៉ះទង្គិចគ្នា ផ្គុំគ្នា ផ្សំគ្នា ហើយកកើតឡើង ។ ភាវៈដែលមានកំណើតឡើងហើយបែបនេះក៏ប្រែប្រួលរីកធំធាត់ ហើយក៏ទ្រុឌទ្រោម និងរលត់ខន្ធទៅវិញ (គឺស្លាប់) ។ រួចហើយទើបមានការប៉ះទង្គិចគ្នា ផ្គុំគ្នា ផ្សំគ្នា

ឡើងជាថ្មីទៀតនាំឱ្យកើតជីវិតថ្មីឡើងយ៉ាងនេះជាដរាបទៅ។

ដរាបណាផលនៃកម្មមិនទាន់ផុតរលត់ទេ ដរាបនោះសត្វលោកនៅតែត្រូវកើតតទៅទៀត។ បើចង់បំបាត់កំណើត ត្រូវបំបាត់ផលនៃកម្មសិន ទើបកំណើតរលត់ទៅដោយឯកឯង។

**ខ-ទស្សនៈមនោនិយម** : ពេលបុគ្គលណាម្នាក់ស្លាប់ គឺរូបកាយរបស់គេទេដែលស្លាប់ តែព្រលឹង ឬអាត្ម័នរបស់គេមិនស្លាប់ទេ។ វានៅរស់បន្តទៀត ហើយហោះហើរទៅចាប់ជាតិថ្មីទៀត។ តាមទស្សនៈរបស់ជនជាតិអារ៉ាប់ ជំនាន់ដើមបានឱ្យដឹងថា នៅពេលជិតដាច់ខ្យល់ស្លាប់ ព្រលឹងរបស់យើងប្រៀបដូចជាដង្កូវបាក់ខ្នងអញ្ចឹង គឺជើងខាងមុខខំរកកន្លែងណាមួយដើម្បីតោងឱ្យជាប់សិន ទើបលែងជើងក្រោយ។ កន្លែងដែលជើងមុខតោងជាប់រួចហើយនោះ គឺជាកន្លែងដែលត្រូវចាប់ជាតិថ្មីទៀត។

សូក្រាត (Socrate) ក៏អញ្ចឹងដែរ នៅពេលដែលគាត់ត្រូវបានតុលាការកាត់ទោសប្រហារជីវិតដោយឱ្យផឹកថ្នាំពុល លោកបាននិយាយនៅគ្រាចុងក្រោយទៅកាន់សាវ័កលោកថា ខ្ញុំមិនតក់ស្លុតចំពោះសេចក្តីស្លាប់ឡើយ ព្រោះថាគឺរូបកាយរបស់លោកទេដែលស្លាប់ រីឯព្រលឹង ឬអាត្ម័នរបស់លោកគ្រូមិនស្លាប់ទេ។ រូបកាយនេះប្រៀបដូចជាគុកដែលឃុំឃាំងព្រលឹងរបស់លោកគ្រូជាយូរឆ្នាំមកហើយមិនឱ្យចេញទៅណារួច។ ពេលនេះជាឱកាសល្អណាស់ដែលជញ្ជាំងគុក (រូបកាយរបស់លោកគ្រូ) ត្រូវរលំរលើងរលាយអាចឱ្យព្រលឹងរបស់ខ្ញុំហោះហើរបានដោយសេរី។

<u>**តាមទស្សនៈវិទ្យាសាស្ត្រ**</u>

ចំពោះពិភពរូបធាតុ ឬពិភពសម្ភារៈនេះ អង្គប្រាណរបស់យើងម្នាក់បានផ្សំឡើងដោយធាតុបង្កសំខាន់ ៤ គឺ : កាបូន (C) អ៊ីដ្រូសែន (H) អុកស៊ីសែន (O) និងនីត្រូសែន ឬអាសូត (N) សរសេរកាត់គឺ CHON ដែលចូលផ្សំជាមួយគ្នាបង្កើតបានជាម៉ូលេគុលសាំញ៉ាំ និងស្មុគស្មាញ និងមានការរៀបចំចាត់តាំងត្រឹមត្រូវល្អឥតខ្ចោះ។ ក្រៅពីនេះនូវមានធាតុបន្ទាប់បន្សំផ្សេងទៀតដូចជា ខនិជ (មានដែក (Fe) ទង់ដែង (Cu) ម៉ាញេស្យូម (Mg) កាល់ស្យូម (Ca) សូដ្យូម (Na) ប៉ូតាស្យូម (K) ផូស្វ័រ (P)... ។ល។)

នៅពេលក្រោយស្លាប់ សពនៃតួខ្លួនប្រាណរបស់យើងអាចត្រូវកប់ ឬបូជា (ដុតបំផ្លាញរូបរាងកាយឱ្យឆេះខ្ទេចខ្ទីទៅជាធូលី ផេះ ផ្សែង ផេះផង់...)។ នៅពេលនោះ វាកើតមានការបែកធាតុនៃសារធាតុសរីរាង្គនៃតួខ្លួនយើងទៅជាសារធាតុគីមីថ្មីផ្សេងទៀត។

តាមច្បាប់រក្សារូបធាតុរបស់លោកឡាវ័រសៀ ជាគីមីវិទូបារាំងបានអះអាងថា "Rien ne se perd, rien ne se crée, tout se transforme" មានន័យថា មិនមានអ្វីបាត់បង់ទៅវិញឯង១ទេ មិនមានអ្វីកើតឡើងឯង១ទេ គឺគ្រាន់តែមានការប្តូររូបរាងប៉ុណ្ណោះ។ បើផ្អែកលើទស្សនៈនេះ គឺអាចមានជាតិថ្មីមួយទៀតក្រោយពីលាចាកលោកនេះទៅ។

ឥឡូវសាកល្បងបកស្រាយដោយផ្អែកលើច្បាប់លោក Lavoisier លមើល : រូបកាយយើងផ្សំដោយធាតុបង្កសំខាន់ ៤ គឺ CHON។ នៅពេលគេដុតរំលាយតួខ្លួនយើង គឺពេលនោះហើយដែលភ្លើងឆាបឆេះសាច់ ឆ្អឹង សក់ សួត ថ្លើម ប្រមាត់ បេះដូង ក្រពះ ពោះវៀន និងអ្វី១ទាំងអស់ប្រែក្លាយទៅជាផ្សែង និងជាផេះផង់។ ក្នុងផ្សែងមានជាតិទឹក គឺ $H_2O$ និងឧស្ម័នកាបូនិច ($CO_2$)។ ក្នុងនោះមានជាតិកាល់ស្យូមផូស្វាតដែលចេញពីឆ្អឹង។

បើកប់តួខ្លួន សពនឹងហើមរលេះរលួយ ស្អុយ កើតជាមេតាន ($CH_4$) ឧស្ម័នអាម៉ូញាក់ ($NH_3$) ឬជានីត្រាត ($NO_3$)

ជាដើម...។ សារធាតុ ឬអង្គធាតុទាំងនេះក្នុងរយៈពេលមួយដែលលក្ខខណ្ឌអនុគ្រោះ ក៏រលាយចូលគ្នាជាមួយទឹក និងដី (ពេលកើតគឺកើតពីដី ទឹក ភ្លើង ខ្យល់ដែរ => ដល់ពេលរលាយរូបទៅវិញក៏ទៅជាដី ទឹក ភ្លើង ខ្យល់វិញដដែល) បង្កើតបានជាប្រភពជីរដែលត្រូវបានរុក្ខជាតិស្លឹកបៃតង (មានជាតិក្លរ៉ូភីល) ស្រូបយកហើយបំផ្លែងទៅជាសារធាតុចិញ្ចឹម (មានជីរជាដើម) តាមបាតុភូតរស្មីសំយោគ។ ដូច្នេះអាតូម CHON និងអាតូមរបស់ខនិជផ្សេងទៀតដែលបែកធ្លាយចេញពីខ្លួនយើងនោះវាក៏ទៅនៅក្នុងស្លឹកឈើ ផ្លែឈើ ផ្កា និងតួដើមឈើនោះអី! (តើអញ្ចឹងមែនទេ? នេះគឺគ្រាន់តែជាការសាកល្បងបកស្រាយតាមទស្សនៈវិទ្យាសាស្ត្រតែប៉ុណ្ណោះ)។ នៅក្នុងដើមរុក្ខជាតិស្លឹកបៃតង កើតមានបាតុភូតរស្មីសំយោគ ឧស្ម័នកាបូនិច $CO_2$ ជាមួយពន្លឺថ្ងៃបង្កើតជា $C_6H_{12}O_6$ (glucose = គ្លុយកូស)។

ប្រតិកម្មរស្មីសំយោគ : $6CO_2 + 6\,H_2O \rightarrow C_6H_{12}O_6 + 6O_2$

ឧទាហរណ៍ : បុគ្គល A => ពេលនៅរស់មានផ្ទុកសារធាតុ CHON និងខនិជដល់ក្រោយពេលស្លាប់ CHON និងខនិជរបស់លោក A នេះបែកខ្ញែកខ្លះទៅនេះ ខ្លះទៅនោះ។ ខ្លះបង្កើតជាជីរចិញ្ចឹមដើមឈើដែលក្នុងនោះមាន CHON និងខនិជរបស់លោក A (គឺវាគ្រាន់តែជាអាតូម CHON និងខនិជរបស់លោក A តែប៉ុណ្ណោះ គឺមិនមែនជាតួខ្លួនលោកកាលនៅរស់នោះទេ)។

ដើមឈើរីកលូតលាស់មានផ្កា មានផ្លែ។ ជួនកាលអាចប្រពន្ធ ឬកូនលោក A ឬអ្នកដទៃទិញផ្លែឈើនោះទៅហូប។ ពេលនោះ CHON របស់លោក A ក៏ចូលទៅក្នុងខ្លួន ក្នុងឈាមក្នុងសាច់របស់ប្រពន្ធកូនលោក A និងក្នុងខ្លួនអ្នកដទៃក្នុង១រយៈពេលនៃជីវិតរស់នៅរបស់ពួកគេ ហើយ CHON របស់លោក A ក៏រស់ជាមួយពួកគេ១រយៈកាលអញ្ចឹងទៅហោង!។

**លោក ម៉េង ស៊ីមហួច**

---

**"ប្រជាជាតិមួយ**
**មានតម្លៃអាស្រ័យដោយ**
**ការអប់រំរបស់ខ្លួន"**

**ភាសិតបារាំង**



# ចិត្តវិទ្យាអប់រំ

## យល់ដឹងអំពីទារកភាព (តចប់)

### III-ការរៀនដំបូង និងលំនឹកដំបូងរបស់ទារក

**១_ការរៀនតាមការធ្វើត្រាប់តាម**

ទោះបីទារកទើបនឹងកើតអាចមានលទ្ធភាពធ្វើត្រាប់តាមបានខ្លះៗក៏ដោយ ក៏មូលដ្ឋាននៃបំណិនប្រសប់ដើម្បីធ្វើត្រាប់តាមអ្នកដទៃរបស់ទារក និងកិរិតតិរិយាបថដែលទារកសំដែងចេញបានផ្លាស់ប្តូរជាលំដាប់ទៅតាមអាយុរបស់គេ។ នៅវ័យដំបូងបង្អស់របស់ទារក គឺប្រហែលអាយុ១ឆ្នាំកន្លះ កុមារចេះធ្វើទូទៅកម្មតិរិយាបថទាំងឡាយដែលបានត្រាប់រួចហើយនោះទៅតាមបរិយាកាសថ្មីបានទៀតផង។

**២_លំនឹក (ការចងចាំ)**

កាលណាការទាញចេញព័ត៌មានរបស់ទារកធ្វើបានត្រឹមត្រូវ ទារកអាចរំលឹកបាននូវព័ត៌មានមួយចំនួនដែលខ្លួនបានរៀនរួចហើយក្នុងរយៈពេលកន្លងមក។

ត្រង់នេះមានន័យថា កុមារត្រូវការតែការរំលឹកណាដែលត្រឹមត្រូវ ដើម្បីជួយគេឱ្យរកឃើញព័ត៌មានដែលគេបានរក្សាទុក។

### IV-ការរៀនដើរ

ការធ្វើចលនាដើរ និងរបៀបឈរ ជាប់ទាក់ទងគ្នាយ៉ាងជិតស្និទ្ធ ជាពិសេសការដើរដងខ្លួនត្រង់។ ការដើរដងខ្លួនត្រង់នេះទាមទារការប៉ិនប្រសប់ក្នុងការបង្កើតលំនឹងនៃការឈរជើងមួយ និងការបោះជំហានប្តូរជើងមួយទៅជើងមួយទៀតដើម្បីដើរទៅមុខកុំឱ្យដួល។

តាមការស្រាវជ្រាវរបស់លោក ការ៉ែន អាដុល (Karen Adolf) បានឱ្យដឹងថា ក្នុងការរៀនដើរនេះ ទារករៀនស្គាល់អំពីប្រភេទនៃទីកន្លែង និងផ្ទៃដែលធានាសុវត្ថិភាពដល់ការងារ ការលូន ឬដើររបស់គេ ដូចជាការវារ ឬការលូនចុះចំណោតលើផ្ទៃជំរាល និងការដើរចុះតាមផ្ទៃជំរាលរបស់ទារកជាដើម។

### V-ការសំដែងចេញនូវការលូតលាស់ចិត្តរំភើបរបស់ទារក

តាមការស្រាវជ្រាវអំពីការលូតលាស់ចិត្តរំភើបរបស់ទារក គេបានកត់សំគាល់ឃើញមានប្រភេទចិត្តរំភើបសំខាន់ពីរ បែបៈ

**១.ចិត្តរំភើបដំបូង** (ជាចិត្តរំភើបកំរិតទាបដែលមានចំពោះមនុស្ស និងសត្វដទៃទៀត) ដូចជាសប្បាយរីករាយ ព្រួយ ភ័យខ្លាច ស្អប់ជាដើម។ ចិត្តរំភើបដំបូងនេះកកើតឡើងក្នុងចន្លោះអាយុ៦ខែដំបូងនៃជីវិតរបស់ទារក។

**២.ចិត្តរំភើបស្វ័យញាណ** : ទាមទារមានការយល់ដឹង (ពុទ្ធិ) ជាពិសេសការកកើត មនសិការ ឬញាណ។ ចិត្តរំភើប ស្វ័យញាណរួមមាន ការយល់ចិត្ត ការច្រណែន ការខ្មាស់អៀន ការខ្វល់ខ្វាយ អរ ការពេញចិត្តជាដើមដែលកកើតឡើងនៅអាយុ១ឆ្នាំកន្លះនៃជីវិតរបស់ទារក។

<u>**រូបភាពខាងក្រោមនេះ ជាគោលសមានៃការរីកចំរើនបំណិនចលនាដើររបស់ទារក**</u>




**<u>ពន្យល់ៈ</u>**

ខ្សែដេក : អាយុគិតជាចំនួនខែ។ ខ្សែឈរ : កំរិតអភិវឌ្ឍន៍បំណិនចលនាដើរ។

<u>**រូបភាពខាងក្រោមបង្ហាញអំពីការសំដែងចេញនូវចិត្តរំភើបផ្សេងៗរបស់ទារក**</u>


សប្បាយរីករាយ


ព្រួយ


ខឹង



ភ័យខ្លាច



ភ្ញាក់ផ្អើល



អរ



យំគាំង (ខឹង)

លោក ម៉េង ស៊ុមហុង

អតីតនាយកមជ្ឈមណ្ឌលបច្ចេកទេស

និងវិជ្ជាជីវៈព្រះកុសុមៈ

# វិបត្តិដំណេក និងផលប៉ះពាល់របស់វា ទៅលើការរៀនសូត្ររបស់សិស្ស

ការលើកយកបញ្ហាដំណេកមកនិយាយនេះ គឺចង់បង្ហាញអំពីផលប៉ះពាល់របស់វាទៅលើការរៀនសូត្ររបស់សិស្សនៅក្នុងសាលា។ មានអ្នកសិក្សាស្រាវជ្រាវជាច្រើននាក់កំពុងចាប់ផ្ដើមយល់អំពីភាពអវិជ្ជមាននៃការដេកមិនគ្រប់គ្រាន់ទៅលើដំណើរសិក្សារៀនសូត្រ។

មុននឹងចូលដល់បញ្ហាស្ដីអំពីកង្វះខាតដំណេក (ឬដេកមិនគ្រប់គ្រាន់) នេះ គប្បីត្រូវពិនិត្យអំពីជីវសាស្ត្រនៃដំណេកសិន។

## តើអ្វីទៅជាដំណេក? តើដំណេកកើតឡើងយ៉ាងដូចម្ដេច?

មានអ្នកវិទ្យាសាស្ត្រជាច្រើននាក់យល់ថា ដំណេកគឺជាខណៈមួយដែលខួរក្បាលមនុស្សយើងនៅស្ងប់ស្ងៀម អកម្ម។ ប៉ុន្តែផ្ទុយទៅវិញ នៅពេលដេកខួរក្បាលរបស់មនុស្សយើងសកម្មណាស់។ យើងទើបនឹងយល់អំពីផលប៉ះពាល់របស់ដំណេកទៅលើសកម្មភាពប្រចាំថ្ងៃ និងទៅលើសុខភាពផ្លូវកាយ និងផ្លូវចិត្តរបស់យើង។

ដំណេកត្រូវបានត្រួតពិនិត្យដោយនាឡិកាជីវសាស្ត្រដែលស្ថិតយ៉ាងជ្រៅក្នុងខួរក្បាល។ គេហៅវាថា ស៊ុបប្រាស៊ីយ៉ាស្មាទិច ណុយក្លេអ៊ីស (Suprachiasmatic nucleus = SCN) ដែលផ្សំឡើងដោយកោសិកាប្រសាទ (ណឺរ៉ូន = neuron) ប្រមាណ ២០ ០០០កោសិកា។ វាស្ថិតនៅជិតអ៊ីប៉ូតាឡាមូស (Hypotalamus) ប៉ែកខាងលើដែលសរសៃអុបទិច ឆ្លងកាត់។

ពន្លឺដែលចូលតាមរេទីន បង្កើតជាសញ្ញា ហើយឆ្លងកាត់តាមសរសៃអុបទិច និងត្រួតពិនិត្យដោយ SCN។ នៅពេលមានភាពងងឹត សញ្ញាពន្លឺថយចុះ ហើយ SCN ក៏បញ្ជាទៅក្រពេញ Pineal Gland ដើម្បីបញ្ចេញអ័រម៉ូនមេឡាតូនីន។




ដោយបរិមាណមេឡាតូនីននៅក្នុងឈាមកើនឡើង វាក៏ធ្វើឱ្យយើងងងុយដេក។ នៅក្នុងខណៈនោះ SCN កែតម្រូវមុខងារនៃសរីរាង្គផ្សេងៗទៀតនៅក្នុងខ្លួនយើងឱ្យមានភាពស៊ីសង្វាក់គ្នាដូចជា សម្ពាធឈាម សីតុណ្ហភាព ការផលិតទឹកនោមដើម្បីត្រៀមខ្លួនដេក។ នៅពេលព្រឹកព្រលឹម កំហាប់មេឡាតូនីនថយចុះ ហើយដំណាក់ភ្ញាក់ពីដេកក៏ចាប់ផ្ដើម។ ដំណើរប្រព្រឹត្តទៅនៃវដ្ដ "ដេក-ភ្ញាក់ ដេក-ភ្ញាក់" ពីដំណេកនេះ គឺជាចង្វាក់ប្រចាំថ្ងៃរបស់យើងម្នាក់ៗដែលមានឈ្មោះថា សៀកាដ្យង់ "circadian"។

ទោះបីការដេក និងការភ្ញាក់ពីដំណេកត្រូវបានលៃតម្រូវដោយសញ្ញាដែលបញ្ជូនពីណឺរ៉ូនផ្សេងៗគ្នានៅក្នុងខួរក្បាលក៏ដោយ ក៏បញ្ហាម្ហូបអាហារ និងឱសថអាចធ្វើឱ្យមានតុល្យភាពនៃសញ្ញាទាំងនោះ និងមានឥទ្ធិពលលើលំនាំដំណេករបស់យើងដែរ។ ឧទាហរណ៍ : ផលិតផលមានជាតិកាហ្វេអ៊ីន សូដា ថ្នាំលេបសំរួលអារម្មណ៍ជាដើម បានភ្ញោចផ្នែកខ្លះនៃខួរក្បាលដែលអាចបង្អាក់ដំណេក។ អ្នកជក់បារីច្រើនមានភ្ញាក់ពីដំណេកច្រើនដងណាស់នៅពេលយប់ដែលបណ្ដាលមកពីជាតិនីកូទីន។ មានអ្នកខ្លះព្យាយាមផឹកស្រានៅមុនពេលដេក ដើម្បីសំរួលដល់ការដេកលក់របស់គេ។ ស្រាអាចជួយឱ្យដេកលក់មែន។ ប៉ុន្តែវាមិនមែនជាដំណេកលក់ស្កប់ស្កល់ទេ។ វាគ្រាន់តែជួយឱ្យពួកគេដេកលក់រលីវប៉ុណ្ណោះ ហើយពួកគេងាយភ្ញាក់ណាស់នៅក្នុងដំណាក់កាលនេះ។

**ដំណាក់កាលទាំងឡាយនៃដំណេក** : ដំណេកមាន ៥ ដំណាក់ជាប់ៗគ្នា ដែលគេហៅថា ដំណាក់ទី១, ទី២, ទី៣, ទី៤ និងចលនាឆាប់រហ័សនៃសាច់ដុំភ្នែក (REM = Rapid Eye Movement)។

| **ដំណាក់កាលទាំង៥ នៃដំណេក និងលក្ខណៈសម្បត្តិរបស់វា** | |
|---|---|
| **ដំណាក់ទី១**: (ដំណេកបណ្ដោះអាសន្ន)<br>១៥នាទី ទៅ ២០នាទី | - ចលនាភ្នែកយឺត (ភ្នែកធ្វើចលនាយឺតណាស់)<br>- សកម្មភាពសាច់ដុំចុះខ្សោយ<br>- អារម្មណ៍អណ្ដែតត្រសែតចេញពីការដេក<br>- ងាយភ្ញាក់ណាស់<br>- នៅពេលភ្ញាក់ពីដំណេក គឺងាយរំលឹកនឹកឃើញអំពីផ្នែកខ្លះនៃរូបភាពដែលបានឃើញ។ |
| **ដំណាក់ទី២** : (ដេកលក់រលីវ មិនទាន់លក់មែនទែន) ១០នាទី ទៅ ១៥នាទី | - ចលនាភ្នែកលែងមានទៀតហើយ<br>- រលកសញ្ញារបស់ខួរក្បាលចុះខ្សោយទៅៗ។ |
| **ដំណាក់ទី ៣** : (ដំណេកលង់លក់)<br>១៥នាទី ទៅ ២០នាទី | - រលកសញ្ញារបស់ខួរក្បាលខ្សោយមែនទែន (ហៅថា រលក "ដែលតា"<br>- ចលនាសាច់ដុំ ឬចលនារបស់ភ្នែកលែងមានទៀតហើយ |
| **ដំណាក់ទី ៤** : (ដំណេកលង់លក់មែនទែន)<br>១៥នាទី ទៅ ២០នាទី | - មានតែរលក ១មុខប៉ុណ្ណោះ<br>- ចលនាសាច់ដុំ ឬចលនារបស់ភ្នែកលែងមានទៀតហើយ<br>- មិនងាយភ្ញាក់ទេ<br>- នៅពេលភ្ញាក់ពីដំណេកមានអារម្មណ៍ងឺងើ និងវង្វេងវង្វាន់មិនដឹងទិសតំបន់ |
| ចលនាឆាប់រហ័សនៃសាច់ដុំភ្នែក : ពី៤ ទៅ ៥ វដ្ដ ក្នុង ១យប់ : ផ្លាស់ប្ដូរប្រែប្រួលពី ១០ ទៅ ៤០នាទី ក្នុង ១វដ្ដ។ | - ដកដង្ហើមញាប់ ខ្លីៗ មិនធម្មតា<br>- ភ្នែកទាញកន្ត្រាក់យ៉ាងឆាប់រហ័សទៅតាមទិសផ្សេងៗ<br>- សាច់ដុំជើងផ្អាកធ្វើចលនាជាបណ្ដោះអាសន្ន<br>- ចលនាបេះដូង និងសម្ពាធឈាមកើន<br>- នៅពេលភ្ញាក់ពីដំណេកគេអាចរំលឹកឃើញ និងពិពណ៌នាអំពីការយល់សប្តិឡើងវិញ<br>- ការផ្ទុកព័ត៌មានក្នុងលំនឹកយូរអង្វែងមានភាពជាប់លាប់ល្អ |

## តើយើងត្រូវការដេកប៉ុន្មានម៉ោងក្នុងមួយថ្ងៃ?

អាយុគឺជាកត្តាមួយសំខាន់ក្នុងការបំពេញតម្រូវការដេករបស់មនុស្សម្នាក់ៗ។ កុមារតូច (ទារក) ត្រូវការដេក ១៦ម៉ោងក្នុង១ថ្ងៃ។ នៅចន្លោះអាយុពី ១ឆ្នាំទៅ៣ឆ្នាំ តម្រូវការដេករបស់ទារកថយចុះមក ១០ទៅ១២ ម៉ោងវិញក្នុង ១ យប់។ ចាប់ពីវ័យនេះទៅដល់យុវវ័យ តម្រូវការដេកតាមធម្មតា គឺ ៩ទៅ១០ម៉ោង។ យុវជនត្រូវការដេក ៨ ទៅ៩ម៉ោង។

មនុស្សធំពេញវ័យភាគច្រើនដេក ៧ទៅ៨ម៉ោង ក្នុង១យប់។ រយៈពេលដេកនេះមិនជាប់ទាក់ទងនឹងប្រាជ្ញា ឬ បុគ្គលិកលក្ខណៈរបស់មនុស្សទេ ថ្វីបើគេដេកបានតិចតួចក៏ដោយ (ករណីលោក Thomas Edison) ឬក៏ដេកបានយូរក៏ដោយ (ករណីលោក Albert Einstein)។

ប្រសិនបើយើងដេកពុំគ្រប់គ្រាន់ទេនោះ សរីរាង្គរបស់យើងទាមទារឱ្យដេកសងវិញឱ្យបានគ្រប់ម៉ោង។ ប្រសិនបើយើងនៅតែបន្តដេកពុំគ្រប់ម៉ោងតាមតម្រូវការរបស់យើងតទៅទៀតនោះ វានឹងធ្វើឱ្យកើតមានការថមថយចុះខ្សោយនៃមុខងារសរីរាង្គផ្សេងៗទៀតនៅក្នុងខ្លួនយើង។

## បើយើងដេកមិនបានគ្រប់គ្រាន់ទេ តើនឹងមានអ្វីកើតឡើង?

ដំណេកត្រឹមត្រូវមានសារៈសំខាន់ណាស់សម្រាប់ធ្វើឱ្យខ្លួនយើងមានសុខភាពធម្មតា។ មានក្មេងគ្រប់អាយុចូលរៀន និងមនុស្សធំពេញវ័យជាច្រើននាក់ដេកមិនបានគ្រប់ម៉ោងទេ។ តាមការសិក្សាស្រាវជ្រាវកន្លងទៅថ្មីៗនេះបានគូសបញ្ជាក់អំពីគ្រោះថ្នាក់នៃការដេកមិនគ្រប់គ្រាន់។ ឧទាហរណ៍ : តាមការធ្វើតេស្តសម្របគ្នារវាងភ្នែក និងដៃរបស់អ្នកដេកមិនគ្រប់គ្រាន់បង្ហាញឱ្យឃើញថា ពួកអ្នកទាំងនេះទទួលលទ្ធផលអាក្រក់ជាងអ្នកស្រវឹងស្រា។

## ហេតុអ្វីបានជាយើងត្រូវការដេក?

ភស្តុតាងជាក់ស្តែងបានបង្ហាញឱ្យឃើញថា ដំណេកមានមុខងារសំខាន់ និងចាំបាច់សម្រាប់ជីវិតរស់នៅរបស់យើងគ្រប់គ្នា។ ប្រសិនបើយើងដេកមិនគ្រប់គ្រាន់ តើនឹងមានអ្វីកើតឡើង?

ដំណេកចាំបាច់ណាស់សម្រាប់សុខភាពនៃប្រព័ន្ធប្រសាទរបស់យើង។ កាលណាយើងដេកបានតិចតួចពេកនោះ យើងមានការលំបាកក្នុងការធ្វើបម្រុងប្រយ័ត្ន។ សុខភាពផ្លូវកាយថយចុះ ហើយល់ទឹករបស់យើងក៏ថយចុះដែរ។ ប្រសិនបើកង្វះខាតដំណេកនេះនៅតែបន្តតទៅទៀតនោះ ភាពវិបល្លាស និងអារម្មណ៍មិននឹងធឹងអាចកើតមានកាន់តែធ្ងន់ធ្ងរឡើងៗ។ សញ្ញាទាំងនេះបានធ្វើឱ្យអ្នកសិក្សាស្រាវជ្រាវទាំងឡាយជឿជាក់ថា ដំណេកបានអនុគ្រោះឱ្យកោសិកាប្រសាទណឺរ៉ូន (ដែលត្រូវបានប្រើប្រាស់នៅពេលយើងភ្ញាក់ពីដេក) មានពេលវេលាដើម្បីសម្រាក និងកែលំអឡើងវិញ។ បើគ្មានការដេកទេនោះ ណឺរ៉ូននឹងវិចរិលទន់ខ្សោយ។

ប្រសិនបើក្មេងៗដេកមិនគ្រប់គ្រាន់ទេនោះ ពួកគេនឹងមានចរិតរាយមាយ ស្មារតីមិនមូលល្អទេ មានភាពឃោរឃៅ មានចរិតប្រឆាំងតបត និងងាយខកចិត្តខូចចិត្ត។ មានភស្តុតាងមួយចំនួនបង្ហាញឱ្យឃើញថា កង្វះខាតដំណេកលង់លក់ស្កប់ស្កល់អាចបណ្តាលឱ្យមានអសមត្ថភាពនៃការសិក្សារៀនសូត្រទៀតផង ថ្វីបើករណីនេះជាករណីកំរកើតមានក៏ដោយ។

(នៅមានត)

លោក ម៉េង ស៊ីមហុង




# ការអភិវឌ្ឍជំនាញវិស្វកម្ម

ការដោះស្រាយបញ្ហាគុណភាពធនធានអ្នកជំនាញវិស្វកម្មធម្មជាតិ ដើម្បីបំពេញតម្រូវការសេដ្ឋកិច្ចសង្គមជាបញ្ហាសំខាន់ដែលតម្រូវឱ្យស្ថាប័នរដ្ឋ ពិសេសអ្នកអប់រំទាំងឡាយខិតខំរកមធ្យោបាយដោះស្រាយជាបន្តបន្ទាប់។ ម្យ៉ាងវិញទៀត យុគសម័យនេះជាយុគសម័យសកលភាវូបនីយកម្ម ជាក់ស្ដែងព្រះរាជាណាចក្រកម្ពុជាជាសមាជិកនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ឬអាស៊ាន និងជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោក (WTO) ដែលធនធានអ្នកជំនាញវិស្វកម្មត្រូវតែមានកម្រិតស្តង់ដារអន្តរជាតិ ទើបអាចប្រកួតប្រជែងបានក្នុងទីផ្សារសម័យទំនើប។ ដោយឡែក វិស័យសេវាកម្មវិស្វកម្មគឺជាប្រភពសេដ្ឋកិច្ចនៃសហសវត្សរ៍នេះ បន្ទាប់ពីវិស័យទេសចរណ៍ និងវិស័យឧស្សាហកម្ម[១]។ តើត្រូវអភិវឌ្ឍន៍ជំនាញវិស្វកម្មយ៉ាងដូចម្ដេចដើម្បីឱ្យវិស្វករជាតិដែលបានបណ្ដុះបណ្ដាលហើយ មានការងារធ្វើ និងទទួលបានចំណូលសមស្របប្រហាក់ប្រហែលវិស្វករនៅបណ្ដាប្រទេសជិតខាងយើង?

## បញ្ញត្តិទូទៅ

ការងារវិស្វកម្ម គឺជាមធ្យោបាយគន្លឹះនៃការអភិវឌ្ឍអាជីពមនុស្ស[២]។ ការងារវិស្វកម្មជួយដោះស្រាយរាល់បញ្ហាសង្គម និងជួយលើកកំពស់ជីវភាពសង្គមបានតាមរយៈការបង្កើតឧបករណ៍ប្រើប្រាស់ ការច្នៃបង្កើតចំណីអាហារ ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធរូបវន្តរបស់សង្គម។ល។ បច្ចុប្បន្ន វិស័យវិស្វកម្មកំពុងពេញនិយមក្នុងសេដ្ឋកិច្ចសមាហរណកម្ម។ ជាក់ស្ដែងក្នុងក្របខណ្ឌអាស៊ានមានការសម្របសម្រួលក្នុងវិស័យពាណិជ្ជកម្ម សេវាកម្ម វិស្វកម្ម ដើម្បីធ្វើឱ្យមានភាពចុះសម្រុងគ្នា និងទទួលបានផលកម្រៃសមស្របរវាងប្រទេសជាសមាជិក។ ដើម្បីមានមូលដ្ឋានយល់ច្បាស់ពីអត្ថប្រយោជន៍បច្ចុប្បន្ននៃជំនាញវិស្វកម្មក្នុងវិស័យពាណិជ្ជកម្ម សេវាកម្ម គប្បីយល់ពីនិយមន័យ និងវិសាលភាពនៃពាក្យដែលមានការពាក់ព័ន្ធដល់វិស័យជំនាញវិស្វកម្មសិន។

ពាក្យវិស្វកម្ម ត្រូវជាមួយភាសាអង់គ្លេសថា Engineering ហើយមានន័យថា ជាមុខវិជ្ជាត្រូវសិក្សា និងជាវិជ្ជាជីវៈដែលជាការអនុវត្តចំណេះដឹងវិទ្យាសាស្ត្រ ការប្រើប្រាស់ច្បាប់ធម្មជាតិ និងធនធានរូបវន្តទាំងឡាយ ដោយរៀបរយ ដើម្បីធ្វើគម្រោង និងបង្កើតប្រព័ន្ធវិធីសាស្ត្រផលិតកម្មឧបករណ៍ បរិក្ខា គ្រឿងចក្រ រចនាសម្ព័ន្ធ តាមតម្រូវការរបស់មនុស្ស និង

(១) www.encyclopedia.com (២) Columbia Encyclopedia, Sixth Edition, 2008

សមស្របតាមលក្ខណៈជាក់ស្ដែង[៣] ។

ពាក្យវិស្វកម្ម មានន័យផ្សេងស្រឡះពីពាក្យ វិទ្យាសាស្ត្រ។ អ្នកវិទ្យាសាស្ត្រសិក្សាដើម្បីស្វែងយល់ពីធម្មជាតិ។ ចំណែកឯវិស្វករខិតខំសិក្សាស្រាវជ្រាវបង្កើតអ្វីៗដែលគ្មានក្នុងធម្មជាតិ។ វិស្វករមានកាតព្វកិច្ចជាចម្បងគឺ ការច្នៃប្រឌិតបង្កើតថ្មី។ អ្នកវិទ្យាសាស្ត្រអាចក្លាយទៅជាវិស្វករ ប្រសិនបើគេទទួលការសិក្សាខាងវិទ្យាសាស្ត្រអនុវត្ត ឬខាងបច្ចេកវិទ្យា ចំណែកឯវិស្វករក៏អាចក្លាយទៅជាអ្នកវិទ្យាសាស្ត្របានដែរ ប្រសិនបើគេបន្តស្រាវជ្រាវដើម្បីរកឃើញអ្វីថ្មីក្នុងធម្មជាតិ។ ជាក់ស្ដែង លោក Willard Gibbs នៃសកលវិទ្យាល័យ Yale នៅសហរដ្ឋអាមេរិក លោកបានទទួលសញ្ញាប័ត្របណ្ឌិតទស្សនវិជ្ជាវិស្វកម្ម និងសញ្ញាប័ត្របណ្ឌិតទស្សនវិជ្ជាវិទ្យាសាស្ត្រព្រមគ្នានៅឆ្នាំ១៩៦៣។

ពាក្យវិស្វកម្ម ត្រូវបានគេយកមកប្រើតាំងពីសម័យបុរាណមកម្ល៉េះ។ លោក Djoser គាត់ប្រហែលជាអ្នករៀបចំគម្រោង និងត្រួតពិនិត្យការសាងសង់ Pyramid នៅ Saqqarah នៃប្រទេសអេហ្ស៊ីបបុរាណរវាងឆ្នាំ ២៦៣០ ដល់ ២៦១១ មុនគ្រឹះសករាជ[៤] ។ វិស័យវិស្វកម្មបានវិវត្តរីកចំរើន និងមានវិសាលភាពពាក់ព័ន្ធដល់ការងារជំនាញទាំងក្នុងផ្នែកយោធា និងផ្នែកស៊ីវិល។ ផ្នែកយោធាមានការសាងសង់លេណដ្ឋាន រថក្រោះ កាណុងធ្លោង និងយុទ្ធោបករណ៍ផ្សេងៗ។ ផ្នែកស៊ីវិលមានការសាងសង់សំណង់សិល្បការ អាគារ កំពង់ផែ បណ្ដាញធារាសាស្ត្រ គ្រឿងចក្រ រោងចក្រ ។ល។ ក្នុងសម័យទំនើប វិស័យវិស្វកម្មមានការពាក់ព័ន្ធដល់វិធីបន្តពន្ធ និងកុំព្យូទ័រ។ វិស័យកុំព្យូទ័របំរើឱ្យវិស័យផ្សេងៗ មានវិស័យអប់រំ (ការប្រើ IT) វិស័យពាណិជ្ជកម្ម (ការប្រើ Software) វិស័យសុខាភិបាល វិស័យរដ្ឋបាលជាដើម។

វិស័យវិស្វកម្មសំខាន់ៗមាន :

- វិស្វកម្មអវកាស : សិក្សា និងផលិតយន្តហោះ យានអវកាស និងឧបករណ៍ផ្សេងៗ
- វិស្វកម្មស៊ីវិល : សិក្សា និងសង់សំណង់សាធារណៈ និងឯកជន មានហេដ្ឋារចនាសម្ព័ន្ធ ស្ពាន និងអគារជាដើម
- វិស្វកម្មគីមី : សិក្សាពីវិធីបំលែងវត្ថុធម្មជាតិឱ្យទៅជារបស់ប្រើប្រាស់ ឬជាអាហារ
- វិស្វកម្មអគ្គិសនី : គូរប្លង់ តំឡើងបំពាក់ប្រព័ន្ធបណ្ដាញអគ្គិសនីសម្រាប់គ្រង់ស្វ ឬឧបករណ៍អគ្គិសនីជាដើម
- វិស្វកម្មមេកានិច : សិក្សាពីបច្ចេកវិទ្យាប្រព័ន្ធមេកានិចនៃគ្រឿងម៉ាស៊ីន។

អាស្រ័យដោយបច្ចេកវិទ្យាវិវត្តជឿនលឿនខ្លាំង មានលេចឡើងនូវសាខាវិស្វកម្មថ្មីៗជាច្រើនទៀត ដូចជាវិស្វកម្មកុំព្យូទ័រ វិស្វកម្ម Software វិស្វកម្មម៉ូលេគុល វិស្វកម្មមេកាត្រូនិចជាដើម ។ល។

ដូចនេះ និយមន័យជារួមនៃពាក្យ វិស្វកម្ម គឺជា "វិទ្យាសាស្ត្រអនុវត្តមុខវិជ្ជាវិទ្យាសាស្ត្រមាន គណិតវិទ្យា រូបវិទ្យា ជីវវិទ្យា ផែនដីវិទ្យា គីមីវិទ្យាជាដើម ដើម្បីបំរើឱ្យតម្រូវការសង្គមដែលវិវត្តឥតឈប់ឈរនេះឯង"។

ពាក្យវិស្វករ ត្រូវជាមួយភាសាអង់គ្លេសថា Engineer គឺជារូបវន្តបុគ្គល អ្នកប្រកបការងារអាជីពក្នុងវិស័យវិស្វកម្មដោយ មានការអនុញ្ញាត និងទទួលស្គាល់ត្រឹមត្រូវ។

ពាក្យវិស្វករនេះដំបូងឡើងគេបានប្រើសម្រាប់សម្គាល់អ្នកបង្កើត និងបញ្ជាម៉ាស៊ីន ក្នុងវិស័យយោធា។ ពាក្យវិស្វករមានប្រភពពីពាក្យឡាតាំង "Ingenium" មានន័យថា អ្នកមានគុណសម្បត្តិពីធម្មជាតិ ពិសេសអនុភាពនៃបញ្ញាដែលអាចផ្ដើមការបង្កើតថ្មីដោយឆ្លាតវៃ[៥] ។

(៣), (៤) & (៥) www: (ibid)

កម្រិតសមត្ថភាពជំនាញវិជ្ជាជីវៈរបស់វិស្វករត្រូវបានបញ្ជាក់ និងផ្តល់ជូនជាគោរម្យងារដែលគោរម្យងារនោះមានឈ្មោះប្រែប្រួលតាមតំបន់ផ្សេងៗនៃពិភពលោក។ នៅក្នុងសហគមន៍អឺរ៉ុប ពិសេសប្រទេសនិយមភាសាបារាំង គេប្រើអក្សរកាត់ Ir. ភ្ជាប់ជាមួយឈ្មោះមនុស្សដែលជាវិស្វករ សម្គាល់ថា ជាវិស្វករអាជីព។ នៅតាមបណ្តាប្រទេសនិយាយភាសាអង់គ្លេស គេនិយមប្រើអក្សរកាត់ P.Eng ហើយនៅសហរដ្ឋអាមេរិកគេប្រើពាក្យ PE ឬ P.Eng។ ដោយឡែកនៅចក្រភពអង់គ្លេសគេប្រើអក្សរ CEng (Chartered Engineer)។ គោរម្យងារវិស្វករអាជីពរបស់វិស្វករត្រូវបានវាយតម្លៃសម្រេចប្រគល់ឱ្យដោយស្ថាប័នវិស្វកម្មជាតិនីមួយៗលើមូលដ្ឋាននៃបទពិសោធន៍ប្រតិបត្តិ និងក្រមសីលធម៌វិជ្ជាជីវៈវិស្វកម្មជាតិ និងស្មារតីនៃកិច្ចព្រមព្រៀងវ៉ាស៊ីនតោន ស្តីពីការត្រួតពិនិត្យផ្តល់តម្លៃជាអន្តរជាតិនៃការទទួលស្គាល់កម្រិតជំនាញវិស្វកម្ម។

សេវាកម្ម ត្រូវជាមួយភាសាអង់គ្លេសថា Service ក្នុងន័យសេដ្ឋកិច្ច សេវាកម្មគឺជាទំនិញអរូបី។ ការផ្គត់ផ្គង់សេវាកម្មគឺជាសកម្មភាពសេដ្ឋកិច្ចដែលមានលក្ខណៈផ្សេងពីការផ្គត់ផ្គង់ទំនិញរូបី មានដូចជាប្រដាប់ប្រដាប្រើប្រាស់ គ្រឿងឧបភោគបរិភោគជាដើម។ អ្នកមានកម្មសិទ្ធិសេវាកម្មអាចទទួលកម្រៃបានមកពីការផ្តល់ភាពងាយស្រួលដល់អតិថិជនតាមរយៈភាពជាម្ចាស់ទ្រព្យរូបី ឬទ្រព្យអរូបី។ ការផ្គត់ផ្គង់សេវាកម្មវិស្វកម្ម គឺជាការផ្តល់កម្លាំងមនុស្សដែលមាន ជំនាញមានទេពកោសល្យ និងមានបទពិសោធន៍ដើម្បីសម្រួលដល់ការលើកគម្រោងការមួយ ឬការអនុវត្តគម្រោងការ មួយ។ អ្នកផ្គត់ផ្គង់សេវាកម្មមិនចាំបាច់មានធនធានបម្រុង ឬវត្ថុធាតុដើមសំពោងសំពាយដូចអ្នកផ្គត់ផ្គង់ទំនិញរូបិយឡើយ។ បច្ចុប្បន្នវិស័យសេវាកម្មគេចាត់ទុកជាវិស័យទីបីក្នុងវិស័យឧស្សាហកម្មដែលមានការផលិតទ្រព្យសម្ភារៈ និងគ្រឿងឧបភោគបរិភោគជាវិស័យទី១ ហើយវិស័យទេសចរណ៍ជាវិស័យទី២។ ក្នុងវិស័យពាណិជ្ជកម្ម សេវាកម្មចែកចេញជា ១៥៥ប្រភេទដែលមានចំណាត់ថ្នាក់ជា ១០ក្រុមសំខាន់ៗ គឺ ÷

- សេវាកម្មពាណិជ្ជកម្មផ្នែកខាងមុខរបរអាជីព (Trade on Professional Services)
- សេវាកម្មទំនាក់ទំនងគមនាគមន៍ (Communication Services)
- សេវាកម្មសាងសង់ និងវិស្វកម្ម (Construction and Engineering)
- សេវាកម្មអប់រំ (Education Services)
- សេវាកម្មបរិស្ថាន (Environment Services)
- សេវាកម្មហិរញ្ញវត្ថុ និងការធានារ៉ាប់រង (Bank and Insurance Services)
- សេវាកម្មសុខភាព (Health Services)
- សេវាកម្មដំណើរកំសាន្ត និងទេសចរណ៍ (Tourism and Travel Services)
- សេវាកម្មកីឡា វប្បធម៌ (Creational, Cultural Sporting Services)
- សេវាកម្មដឹកជញ្ជូន (Transport Services)។

(នៅមានត)

លោក មាស សុខុម

សាស្ត្រាចារ្យផ្នែកទេពកោសល្យស៊ីវិល

នៃវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា




## ការតុបតែងបន្ទប់រៀន

### ក.អ្វីទៅដែលហៅថា ការតុបតែង?

ការតុបតែង គឺជាការរៀបចំបង្កើត លំអឱ្យសមស្របទៅតាមចំណង់ចំណូលចិត្ត ដោយផ្សំនឹងឧបនិស្ស័យសិល្បៈរបស់បុគ្គល។ ការតុបតែងអាចមានសភាពមធ្យម ឬសភាពឆើតឆាយស្រេចទៅតាមកម្រិតសិល្បារម្មណ៍របស់អ្នកតុបតែង។ តាមធម្មតាការតុបតែងគ្រប់បែបយ៉ាងតាំងពីខ្លួនប្រាណ សម្លៀកបំពាក់ របស់ប្រើប្រាស់រហូតដល់ទីលំនៅ ភូមិស្រុក តែងតែអាស្រ័យជាប់ទៅនឹងសម័យកាល ទៅនឹងកន្លែងរស់នៅ ទៅនឹងទឹកដី ធាតុអាកាស ទៅនឹងជំនឿទំនៀមទម្លាប់របស់មនុស្សជាដរាប។ អាស្រ័យហេតុនេះហើយបានជាមានការតុបតែង ពិសេសៗរបស់ជនជាតិនីមួយៗ។ គុណ-សម្បត្តិរបស់មនុស្សក៏ស្ថិតនៅលើការតុបតែងបង្កើតលំអនេះមួយផ្នែកដែរ។

### ខ.ហេតុអ្វីបានជាគេត្រូវតុបតែងបន្ទប់រៀន?

បន្ទប់រៀន ក៏ដូចសាលារៀនដែរ គឺពុំមែនគ្រាន់តែជាកន្លែងសម្រាប់សិស្សរៀន និងកន្លែងសម្រាប់គ្រូបង្រៀនប៉ុណ្ណោះទេ ក៏ប៉ុន្តែជាកន្លែងអប់រំចិត្តគំនិត កិរិយាមារយាទ សោភ័ណភាព របៀបរៀបរយ ការសំអាតថែមទៀត។ និយាយឱ្យខ្លីមក បន្ទប់រៀនគឺជាបន្ទប់នៅទីពីររបស់សិស្ស បន្ទាប់ពីបន្ទប់នៅក្នុងផ្ទះមក។ មួយភាគបី ឬកន្លះភាគនៃជីវិតសិស្សត្រូវរស់នៅក្នុងបន្ទប់រៀននេះ។ សកាពលក្ខណៈនៃបន្ទប់រៀននីមួយៗដែលជីវិតសិស្សបានឆ្លងកាត់ពីសាលារៀនមួយទៅសាលារៀនមួយ ដូចជាបន្ទប់ចាស់ទ្រុឌទ្រោម បន្ទប់ថ្មីសន្លាង បន្ទប់សើមឆ្អេះ បន្ទប់ងងឹតថប់ បន្ទប់ប្រណិត មានឥទ្ធិពលធំធេង និងខ្លាំងក្លាដោតមាំនៅក្នុងស្មារតីចងចាំរបស់សិស្សម្នាក់ៗជានិច្ច។ ដូចនេះ បើយល់ច្បាស់ថាបន្ទប់រៀនជាកន្លែងបង្ហាត់បង្រៀនផង ជាកន្លែងអប់រំសោភ័ណភាពផង គួរណាស់តែរៀបចំតុបតែងបន្ទប់រៀននេះផងដែរ ពីព្រោះទម្លាប់ធ្លាប់តុបតែងបន្ទប់រៀននឹងក្លាយទៅជាទម្លាប់តុបតែងបន្ទប់នៅនឹងផ្ទះសម្បែងរបស់ខ្លួនថែមទៀត។

### គ.ប្រយោជន៍អ្វីបានជាគេត្រូវតុបតែង?

ការសិក្សារៀនសូត្រក្នុងឆ្នាំសិក្សានីមួយៗដែលមានថេរវេលាមិនទាបជាងប្រាំមួយខែ បន្តពីម៉ោងមួយទៅម៉ោងមួយ ពីថ្ងៃមួយទៅថ្ងៃមួយ បានញ៉ាំងសិស្ស និងគ្រូឱ្យនឿយហត់ជាខ្លាំង មិនត្រឹមតែនឿយហត់ប៉ុណ្ណោះទេ ថែមទាំងព្រួយបារម្ភចំពោះកិច្ចការប្រឡងទៀត ចំពោះសិស្សណាដែលត្រូវប្រឡង។ សិស្សហត់នឿយត្រូវការណាស់នូវការសម្រាក

កាយ ការលំហែចិត្ត ការបណ្ដែតអារម្មណ៍មួយដងមួយកាល។ តាមការពិត ការសម្រាកកាយ ការលំហែចិត្ត ការបណ្ដែតអារម្មណ៍មានច្រើនបែបច្រើនយ៉ាងណាស់ទៅតាមចំណូលចិត្តតែរៀង១ខ្លួនទាំងក្នុង ទាំងក្រៅបន្ទប់រៀន សាលារៀន ផ្ទះសម្បែង។ ការតុបតែងបន្តិចបន្តួចក្នុងបន្ទប់រៀនមើលមួយភ្លែតហាក់ដូចជាគ្មានប្រយោជន៍អ្វីឡើយ ក៏ប៉ុន្តែក្នុងចន្លោះបរិយាកាសសិក្សាដ៏តឹងរ៉ឹង ដ៏មធ្យ៉ត បើគ្មានលទ្ធភាពទៅសប្បាយរីករាយក្នុងធម្មជាតិ ឬតាមចំណង់ចិត្ត យ៉ាងហោចណាស់ក៏សិស្សអាចទទួលសេចក្ដីសប្បាយរីករាយដែលលេចចេញមកពីការទស្សនារូបគូរ រូបថត វត្ថុឆ្លាក់ វត្ថុតុបតែងនានាដែលបិទព្យួរតាំងនៅក្នុងបន្ទប់រៀនរបស់ខ្លួនបានមួយគ្រាដែរ។

យើងឃើញរួចមកហើយថា សភាពស្រស់ សភាពល្អ សភាពប្លែកនៃវត្ថុតុបតែងអាចទៅជាជំនួយមួយតូច តែសំខាន់ជួយសម្រាកសម្រាលសេចក្ដីនឿយហត់របស់សិស្ស។ នៅមានប្រយោជន៍មួយទៀតដែលការតុបតែងផ្ដល់ឱ្យគឺសេចក្ដីស្រឡាញ់បន្ទប់រៀន។

សេចក្ដីស្រឡាញ់បន្ទប់រៀន មួយផ្នែកធំកើតចេញមកពីការតុបតែង។ កាលណាសិស្សយកវត្ថុផ្ទាល់ខ្លួនមកតុបតែងបន្ទប់រៀនជាស្នាដៃក៏មាន ជាវត្ថុកម្មសិទ្ធិក៏មាន កាលនោះសិស្សម្ចាស់របស់មានសេចក្ដីពេញចិត្ត និងឱ្យតំលៃជានិច្ចទៅទ្រព្យធនទាំងនោះ។ បើសិស្សម្នាក់១យកវត្ថុសិល្បៈមកតុបតែងឆ្លាស់គ្នាម្ដងម្នាក់១ សេចក្ដីស្រឡាញ់ចំពោះវត្ថុផ្ទាល់ខ្លួនតាំងនៅកន្លែងរួមមួយបានបង្កើតឱ្យមានសេចក្ដីស្រឡាញ់ចំពោះបន្ទប់រៀនទាំងមូល។ សេចក្ដីស្រឡាញ់បង្កើតនូវការឱ្យតំលៃ ហើយការឱ្យតំលៃនឹងបង្កើតនូវការថែរក្សាការពារ ជាហេតុនាំឱ្យឃើញថា ការថែរក្សាការពាររបស់ទ្រព្យឯកជននាំសិស្សឱ្យចេះថែរក្សាការពារបន្ទប់រៀនដែលជាសម្បត្តិរដ្ឋ។

បន្ថែមមកទៀត សេចក្ដីស្រឡាញ់ចំពោះវត្ថុតុបតែងនេះមានប្រយោជន៍នាំសិស្សឱ្យស្រឡាញ់បន្ទប់រៀន និងការសិក្សាក្នុងបន្ទប់រៀននេះដោយបំបាត់ចោលនូវការខ្ជិច ស្អប់ថ្នាក់។

ជាចុងក្រោយ ការតុបតែងអប់រំសិស្សឱ្យមានឧបនិស្ស័យសិល្បៈឱ្យស្រឡាញ់សោភ័ណភាព ឱ្យចេះធ្វើសហប្រតិបត្តិការរៀបចំកន្លែងតុបតែង និងវត្ថុតុបតែងឱ្យមានសាមគ្គីភាពជាមួយគ្រូ-សាស្ត្រាចារ្យ និងទីចាត់ការ។

### ឃ_ របស់អ្វីខ្លះដែលគេយកមកតុបតែង?

របស់តុបតែងមានច្រើនបែបច្រើនយ៉ាង តែបើគេយកមកតុបតែងក្នុងបន្ទប់រៀនវិញ ប្រភេទ សភាព លក្ខណៈ នៃវត្ថុតុបតែងត្រូវមានព្រំរបង។ វត្ថុដែលមិនត្រូវយកមកតុបតែងក្នុងបន្ទប់រៀនមានដូចតទៅ :

- វត្ថុតុបតែងទាក់ទងទៅនឹងការផ្សាយពាណិជ្ជកម្ម
- វត្ថុតុបតែងទាក់ទងទៅនឹងការផ្សាយភាពយន្ត ល្ខោន របាំ
- វត្ថុតុបតែងទាក់ទងទៅនឹងការផ្សាយមនោគមវិជ្ជាបរទេស
- វិយោលក្រដាស ឬផ្កាក្រដាសដែលមានឥទ្ធិពលប្រែសភាពបន្ទប់រៀនទៅជារោងបុណ្យ។ រីឯវត្ថុដែលត្រូវយកមកតាំងជាដាច់ខាតមានដូចជា :
    - ព្រះពុទ្ធរូប
    - ព្រះឆាយាលក្ខណ៍របស់ព្រះមហាវីរក្សត្រ ព្រះមហាក្សត្រីវររាជមាតា ព្រះមហាក្សត្រ
    - បាវចនា ជាតិ សាសនា ព្រះមហាក្សត្រ។

ចំពោះការតុបតែងដែលត្រូវតែប្តូរជារៀងរាល់ខែ ឬរៀងរាល់ត្រីមាសគួរតែជ្រើសរើសសំរាំងដោយប្រមូលផ្ដុំយកវត្ថុដូចតទៅ :

- ផ្ទាំងពុទ្ធោវាទជាភាសាខ្មែរ
- ផ្ទាំងព្រះរាជឱវាទរបស់សម្តេចឪព្រះមហាវីរក្សត្រ និងព្រះមហាក្សត្រ
- ផ្ទាំងសុភាសិត ពិសេសជាខ្មែរ
- ផ្ទាំងរូបគូរ រូបថត អំពីទេសភាព អំពីសិល្បៈ អំពីប្រពៃណី អំពីវិទ្យាសាស្ត្រ...
- វត្ថុសិល្បៈដូចជា រូបឆ្លាក់ រូបផ្តុំ គ្រឿងដេរប៉ាក់ ដែលជាលទ្ធផលនៃការអនុវត្តនីវិជ្ជា សកម្មភាពប្រតិបត្តិគ្រប់ផ្នែក
- ចូដាក់បាច់ផ្កាស្រស់តាំងលើតុគ្រូ-សាស្ត្រាចារ្យ ។ ហើយបើមានលទ្ធភាពអាចធ្វើទៅបាន គួរបន្ថែមវត្ថុតុបតែងដូចតទៅនេះទៀត ៖
    - ផើងដើមឈើស្រស់មួយ ឬពីរ ដាក់នៅជ្រុងបន្ទប់ ដើម្បីបង្កើតសភាពត្រជាក់ត្រជុំ ស្រស់បំព្រៃ
    - កម្រាលតុគ្រូ-សាស្ត្រាចារ្យ ។

ជាសេចក្តីបញ្ជាក់ ផែនទីភូមិសាស្ត្រ ប្រវត្តិសាស្ត្រ ផ្ទាំងរូបសំណាក ផ្ទាំងរូបគំនូរ ផ្ទាំងរូបមន្តនៃមុខវិជ្ជា វិទ្យាសាស្ត្រ ពុំមានលក្ខណៈពេញលេញជាវត្ថុតុបតែងឡើយ តែគេអាចយកមកតុបតែងបានមួយដងមួយកាលក្នុងសម័យសិក្សាមេរៀន ដែលមានការទាក់ទងទៅនឹងផែនទី ផ្ទាំងរូប និងរូបមន្តទាំងនោះ ដើម្បីជួយសម្រួលការចងចាំមេរៀនចំពោះសិស្ស ។ ក្រោយការសិក្សាចប់មេរៀនទាំងនោះ គេត្រូវតែដោះចេញភ្លាម ពីព្រោះវត្ថុទាំងនោះទាក់ទងទៅនឹងការសិក្សាសុទ្ធសាធពុំមែនបង្កើតនូវសេចក្តីសប្បាយរីករាយ លម្ហែចិត្តចំពោះសិស្សឡើយ ។

គួរកត់សម្គាល់ថា វត្ថុប្រកបដោយសោភ័ណភាពពុំមែនសុទ្ធតែជាវត្ថុមានតម្លៃខ្ពង់ខ្ពស់ ហើយមកពីបរទេសនោះឡើយ ។

( នៅមានត)

**លោក ឡុច ផ្លែង**
**អធិការបច្ចេកទេសមធ្យមសិក្សា**
(សម័យសង្គមរាស្ត្រនិយម)

# ការដឹកនាំ និងការគ្រប់គ្រង

**តើមានអ្វីខុសគ្នារវាងការដឹកនាំ និងការគ្រប់គ្រង?**

មតិមួយលើកឡើងថា ភាពខុសគ្នារវាងការដឹកនាំ និងគ្រប់គ្រងស្ថិតនៅលើការប្រព្រឹត្តជាមួយវត្ថុ ឬជាមួយមនុស្ស។ គេបានលើកឡើងថា ការគ្រប់គ្រង ជាការរៀបចំចាត់ចែងផ្តល់នូវវត្ថុ ដូចជាការធ្វើកាលវិភាគសិក្សា ការបំពេញទម្រង់ចំណាយ ការធ្វើរបាយការណ៍ ការបញ្ជាទិញ និងការទទួលនូវសៀវភៅសិក្សា សម្ភារៈការិយាល័យ ការថែរក្សាទីធ្លាសាលារៀនឱ្យស្អាតស្រស់បំព្រងជានិច្ច ការកសាងរបងសាលា។ល។ ផ្ទុយទៅវិញ ការដឹកនាំជាការធ្វើការជាមួយមនុស្ស ជំរុញលើកទឹកចិត្តពួកគេឱ្យប្រឹងប្រែងធ្វើការ បណ្តុះពួកគេឱ្យផ្លាស់ប្តូរនូវឥរិយាបថ និងការជឿជាក់របស់គេ ជួយទ្រទ្រង់ពួកគេឱ្យមានការរីកចម្រើន ជួយពួកគេក្នុងការបំពេញកិច្ចការប្រចាំថ្ងៃរបស់គេ។ យើងជាអ្នកដឹកនាំកាលណាយើងធ្វើការជាមួយមនុស្សធ្វើឱ្យគេអាចជួយឱ្យសាលារៀនក្លាយជាកន្លែងកាន់តែល្អប្រសើរឡើងសម្រាប់សិស្សរៀន។

ការអធិប្បាយអំពីភាពខុសគ្នារវាងការដឹកនាំ និងការគ្រប់គ្រងខាងលើនេះហាក់ដូចជាច្បាស់លាស់ហើយ ប៉ុន្តែជាញឹកញយតែងមានសំណួរលើកឡើងអំពីឈ្មោះមួយដែលនិយាយថា "ការគ្រប់គ្រងធនធានមនុស្ស"។ តើការគ្រប់គ្រងធនធានមនុស្សជាការគ្រប់គ្រង ឬជាការដឹកនាំ? ការគ្រប់គ្រងធនធានមនុស្ស ប្រសិនបើគ្រាន់តែជាការចាត់ចែងគ្រូឱ្យទទួលភារកិច្ចតាមសមត្ថភាពរបស់គេ ឬការចាត់តាំងឱ្យគេកាន់នូវការងារណាមួយនោះ វាគឺជាការគ្រប់គ្រង។ ប៉ុន្តែប្រសិនបើជាការធ្វើការជាមួយពួកគេដោយលើកទឹកចិត្ត ជំរុញ ឬបណ្តុះពួកគេឱ្យចេះគិតបែបប្រឌិតញាណ ឬផ្លាស់ប្តូររបៀបធ្វើការរបស់គេនោះ ពេលនោះវាជាការដឹកនាំ។ ដូចនេះ ការគ្រប់គ្រងធនធានមនុស្សអាចជាការគ្រប់គ្រង ឬដឹកនាំអាស្រ័យដោយការប្រតិបត្តិរបស់នាយកសាលា។

ការសិក្សាស្រាវជ្រាវមួយទៀតបានបង្ហាញនូវភាពខុសគ្នារវាងការដឹកនាំ និងការគ្រប់គ្រង តាមចំណុចមួយចំនួនដូចខាងក្រោម ÷

### ១-ដឹកនាំគឺផ្តើមគំនិត ឯគ្រប់គ្រងគឺចម្លងតាម

ចម្លងតាម គឺធ្វើដដែលៗតគ្នាពីមួយទៅមួយ ឯផ្តើមគំនិតគឺបង្កើតថ្មី បង្ហាញនូវវិធីថ្មី គំនិតថ្មី។ ឧទាហរណ៍ជាក់ស្តែងមួយដែលបានកើតឡើងពិតប្រាកដនៅសាលារៀនមួយ ដើម្បីឆ្លុះបញ្ចាំងនូវគំនិតនេះ។ អង្គការក្រៅរដ្ឋាភិបាលមួយបានសាកល្បងកម្មវិធីឥណទាននៅសាលារៀនមួយដោយផ្តល់នូវថវិកាមួយចំនួនសម្រាប់ជាដើមទុនចាប់ផ្តើម។ គំរូនេះត្រូវបានពង្រីកដល់សាលាផ្សេងទៀត។ នាយកសាលាទាំងនោះបានសហការយ៉ាងល្អជាមួយអង្គការនេះអនុវត្តតាមរបៀបដូចគ្នានេះក្នុងសាលារៀនរបស់ខ្លួន។ ពួកគេធ្វើតាម ឬចម្លងតាម? ប៉ុន្តែមាននាយិកាម្នាក់បានគិតឃើញនូវគំនិតថ្មីមួយ។ ជាជាងរង់ចាំនូវការឧបត្ថម្ភរបស់អង្គការនេះ គាត់គិតថា ត្រូវបង្កើតទុនដោយខ្លួនឯង ដូចនេះគាត់ក៏កោះប្រជុំបុគ្គលិកគាត់ទាំងអស់ បង្ហាញគំនិតរបស់គាត់ ពន្យល់គេឱ្យយល់ និងជឿជាក់តាមគាត់ ហើយធ្វើសំណូមពរសុំខ្ចីពួកគេនូវទឹកប្រាក់មួយចំនួនសម្រាប់ជាដើមទុនចេញដំណើរ។ បួនឆ្នាំបន្ទាប់មក សាលាបានបង្វិលប្រាក់ដើមសងបុគ្គលិកវិញទាំងអស់ ព្រមទាំងបានសន្សំ

បាននូវដើមទុនមួយចំនួនសម្រាប់អនុវត្តបន្តនូវកម្មវិធីឥណទានរបស់ខ្លួន។ យើងអាចនិយាយថា នាយិការូបនេះបានបង្កើតនូវវិធីមួយថ្មីសម្រាប់ការធ្វើឥណទានក្នុងសាលា គាត់គឺជាអ្នកដឹកនាំ។

តទៅនេះ ជាឧទាហរណ៍មួយទៀតសម្រាប់រំលេចគំនិតនេះ។ បន្ទាប់ពីបានធ្វើទស្សនកិច្ចសិក្សានៅសាលារៀនមួយរួចហើយនោះ នាយកសាលាទាំងអស់មើលឃើញថា ការបង្កើតបណ្ណាល័យក្នុងសាលាជាយុទ្ធសាស្ត្រប្រកបដោយប្រសិទ្ធភាពមួយក្នុងការធានាឱ្យការសិក្សារបស់សិស្សបានប្រកបដោយគុណភាព។ ប៉ុន្តែពួកគេជួបប្រទះនូវបញ្ហាមួយធំ គឺកង្វះបណ្ណារក្ស។ នាយកសាលាមួយរូបសម្រេចថា ត្រូវរង់ចាំរហូតដល់មានបណ្ណារក្សសិនបង្កើតបណ្ណាល័យ។ នាយកសាលាមួយទៀតបានលើកបញ្ហានេះទៅពិភាក្សាជាមួយសហគមន៍ ហើយសហគមន៍របស់សាលាបានពេញចិត្តជួយធ្វើការជាបណ្ណារក្ស។ នាយកសាលាទីបីបានចាត់ចែងឱ្យសិស្សថ្នាក់ធំឆ្លៀតពេលដែលទំនេរក្នុងមួយពេលប្រាំនាក់ចូលជួយដំណើរការបណ្ណាល័យក្រោមការគ្រប់គ្រងរបស់នាយករងរបស់គាត់។ ដោយគាត់បានផ្ដួចផ្ដើមនូវគំនិតថ្មីសម្រាប់បង្កើតបណ្ណាល័យក្នុងសាលារបស់ខ្លួននោះ នាយកសាលាទីពីរ និងទីបី ជាឧទាហរណ៍ល្អមួយនៃការដឹកនាំ។

ព្រះបាទជ័យវរ្ម័នទី៧ ក៏យ៉ាងនេះដែរ។ ប្រសិនបើព្រះអង្គគ្រាន់តែចម្លងតាមនូវអ្វីដែលស្ដេចសោយរាជ្យមុនព្រះអង្គមានដូចជាព្រះបាទសុរិយាវរ្ម័នទី២ ជាដើមនោះ ព្រះអង្គពិតជាមិនអាចទទួលបាននូវភាពល្បីល្បាញបានទេ ព្រោះអង្គវត្តបានឈានដល់កម្រិតកំពូលរបស់ខ្លួនរួចទៅហើយ។ ប្រការដែលព្រះបាទជ័យវរ្ម័នទី៧ បានមានភាពល្បីល្បាញដែរនោះ ព្រោះព្រះអង្គបានបង្កើតនូវរចនាបថថ្មីមួយគឺ ប្រាសាទបាយ័ន។

## ២-ដឹកនាំគឺបង្កើត ឯការគ្រប់គ្រងគឺរក្សាទុក

រក្សាទុករបស់អ្វីមួយ គឺថែរក្សាឱ្យគង់នូវភាពដើមរបស់វា ឯបង្កើតគឺធ្វើឱ្យវត្ថុថ្មីៗកើតឡើងជាបន្តបន្ទាប់។ នាយកសាលាជាច្រើនរមែងគិតថា សាលារបស់ខ្លួនល្អគ្រប់គ្រាន់ហើយ មិនត្រូវការធ្វើអ្វីទៀតទេ។ ជួនកាលគាត់គិតថា ការណែនាំពីថ្នាក់លើ ឬផែនការដែលថ្នាក់លើដាក់ចុះមកនោះល្អគ្រប់គ្រាន់ហើយ ហេតុអ្វីចាំបាច់ត្រូវប្រែប្រួលថែមទៀត? ប្រការនេះធ្វើឱ្យសាលារបស់គាត់ស្ថិតនៅតែក្នុងបច្ចុប្បន្នកាល និងធ្លាក់ទៅជាយថាហេតុក្នុងអតីតកាល។ ក៏ប៉ុន្តែក៏មាននាយកសាលាមួយចំនួនស្រេកឃ្លានជានិច្ច និងធ្វើឱ្យសាលារបស់គាត់ប្រែប្រួល។ គាត់គិតពីការកែលំអទីធ្លាសាលារៀនឱ្យកាន់តែមានភាពស្រស់បំព្រងមានការទាក់ទាញអារម្មណ៍កុមារឱ្យចង់មករៀន ធ្វើឱ្យមានការប្រែប្រួលក្នុងការសិក្សារបស់សិស្ស បន្ថែមសៀវភៅថែមទៀតក្នុងបណ្ណាល័យ បញ្ចូលការអប់រំបច្ចេកទេសកសិកម្មទៅក្នុងសាលា។ល។ ដោយគិតជានិច្ចកាលឱ្យសាលារបស់គាត់ប្រែប្រួលយ៉ាងនេះ គាត់បានជួយឱ្យសាលារបស់គាត់មានភាពប្រកួតប្រជែងរីកលូតលាស់ ព្រមទាំងបង្កឱកាសឱ្យមន្ត្រីរបស់គាត់មានការរីកចម្រើន។ ដោយហេតុនេះ យើងអាចនិយាយថា គាត់គឺជាអ្នកដឹកនាំដ៏ពូកែ។

## ៣-ដឹកនាំគឺបណ្ដុះទំនុកចិត្ត ឯគ្រប់គ្រងគឺត្រួតត្រា

ភាពខុសគ្នាមួយទៀតរវាងការដឹកនាំ និងការគ្រប់គ្រងស្ថិតនៅលើសមត្ថភាពអ្នកដឹកនាំក្នុងការបណ្ដុះទំនុកចិត្តដល់មន្ត្រី ចំណែកឯអ្នកគ្រប់គ្រងនិយមការត្រួតត្រាមន្ត្រីរបស់ខ្លួន។ ប្រសិនបើមន្ត្រីទាំងឡាយត្រូវទទួលនូវការត្រួតត្រាជាប់ជានិច្ចនោះ ពួកគាត់នឹងបាត់បង់អស់នូវទំនុកចិត្តផ្ទាល់ខ្លួន ហើយខ្លាចមិនហ៊ានបញ្ចេញគំនិត ឬសាកល្បងគំនិតថ្មី។ ពួកគេនឹងរង់ចាំតែការណែនាំ ហើយធ្វើតាមជានិច្ចនូវអ្វីដែលត្រូវបានណែនាំ។ ដូចនេះ នាយកសាលាក៏ធ្វើការតែម្នាក់ឯង។ អ្នកដឹកនាំល្អទុកចិត្តមន្ត្រីរបស់ខ្លួន។ គាត់ស្មោះត្រង់ជាមួយពួកគេ ហើយបើកចំហទទួលនូវមតិយោបល់របស់ពួកគេ។ ធ្វើយ៉ាងនេះគឺ

គាត់បណ្ដុះមន្ត្រីរបស់គាត់ឱ្យជឿជាក់លើសមត្ថភាពរបស់ខ្លួន ហើយជាលទ្ធផលមន្ត្រីទាំងនោះកាន់តែបណ្ដុះបាននូវស្វ័យទំនុកចិត្តសមត្ថភាពកាន់តែកើនឡើងព្រមទាំងចូលរួមពេញលេញក្នុងគ្រប់សកម្មភាពរបស់សាលា។ ប្រការនេះនាំឱ្យសាលាចេះតែរីកចម្រើនជាបន្តបន្ទាប់។ ឧទាហរណ៍ខាងលើស្ដីពីនាយិកាសាលារៀនមួយដែលមានគំនិតផ្ដើមពីកម្មវិធីឥណទានក្នុងសាលានោះមានន័យគ្រប់គ្រាន់សម្រាប់ឆ្លុះបញ្ចាំងនូវទស្សនៈបណ្ដុះទំនុកចិត្តនេះ។ មន្ត្រីក្នុងសាលាពិតជាពុំផ្ដល់ប្រាក់របស់គេឱ្យសាលាខ្ចីធ្វើជាដើមទុនទេ ប្រសិនបើគេមិនមានទំនុកចិត្តចំពោះនាយិការបស់គេទេនោះ។

## ៤_ដឹកនាំគឺសម្លឹងមើលវែងឆ្ងាយទៅមុខ ឯគ្រប់គ្រងគឺគិតត្រឹមការងារចំពោះមុខ

គិតត្រឹមរយៈពេលខ្លីគឺគិតត្រឹមបច្ចុប្បន្ន ត្រឹមមួយថ្ងៃ មួយខែ មួយសប្ដាហ៍ ឬមួយឆ្នាំ។ ការគិតត្រឹមបច្ចុប្បន្នជាការងាយស្រួល ប៉ុន្តែការសម្លឹងត្រឹមតែរយៈពេលខ្លីមិនអាចជួយឱ្យសាលារៀនមានការអភិវឌ្ឍទេ។ មូលហេតុដែលព្រះបាទជ័យវរ្ម័នទី ៧ មានជោគជ័យក្នុងការស្ថាបនាឡើងនូវប្រទេសកម្ពុជា ធ្វើឱ្យកម្ពុជាមានការរីកចម្រើនដល់កម្រិតកំពូលនោះគឺដោយសារព្រះអង្គមានមហិច្ឆតាខ្ពស់ សម្លឹងមើលទៅមុខវែងឆ្ងាយ និងរៀបចំច្បាស់លាស់នូវផែនការដែលព្រះអង្គត្រូវធ្វើទៅអនាគត។ យើងអាចនិយាយថា ព្រះអង្គមានយថាទស្សន៍វែងឆ្ងាយទៅមុខ។ អ្នកដឹកនាំដែលមានប្រសិទ្ធភាពចាប់ផ្ដើមពីការកសាងនូវយថាទស្សន៍វែងឆ្ងាយទៅមុខ។ គេត្រូវបង្កើតនូវចក្ខុវិស័យ កំណត់នូវទិសដៅត្រូវធ្វើឱ្យសម្រេចទៅថ្ងៃអនាគត បន្ទាប់មកបង្កើតនូវផែនការដើម្បីធ្វើឱ្យសម្រេចចក្ខុវិស័យនោះ។

## ៥_ដឹកនាំគឺសួរពីអ្វី និងហេតុអ្វី ឯគ្រប់គ្រងគឺសួរពីពេលណា

ពេលណាត្រូវបានដាក់ឱ្យធ្វើអ្វីមួយ អ្នកគ្រប់គ្រងរមែងសួរថា តើអ្នកចង់ឱ្យធ្វើហើយនៅពេលណា? ឬសូមប្រាប់ខ្ញុំនូវកាលបរិច្ឆេទច្បាស់លាស់សម្រាប់ការងារនេះ។ គេផ្ដោតត្រឹមតែលើការធ្វើឱ្យហើយ មិនបានផ្ដោតលើលទ្ធផលទេ។ ផ្ទុយទៅវិញ អ្នកដឹកនាំរមែងយកចិត្តទុកដាក់ជាចំបងលើលទ្ធផល។ មុនពេលធ្វើអ្វីមួយ ជានិច្ចកាលគេសួរថា តើត្រូវធ្វើអ្វី និងហេតុអ្វីត្រូវធ្វើជាសំណួរចង់ដឹងពីការងារដែលត្រូវធ្វើ និងមូលហេតុដែលត្រូវធ្វើ។ ការដឹងពីអ្វីដែលត្រូវធ្វើនោះអាចជួយឱ្យគេធ្វើការវិភាគបានល្អ ហើយបើគេយល់ពីមូលហេតុច្បាស់លាស់ទៀត គេអាចពន្យល់មន្ត្រីរបស់គេឱ្យជឿតាមជំរុញលើកទឹកចិត្តពួកគេអនុវត្ត និងលើកកម្ពស់ការចូលរួមបានពេញលេញ។

## ៦_ដឹកនាំគឺគិតគ្រប់ជ្រុងជ្រោយ ឯគ្រប់គ្រងគឺគិតត្រឹមចំណុចសំខាន់ៗ

ចំពោះមុខបញ្ហាណាមួយ អ្នកគ្រប់គ្រងច្រើនផ្ដោតការយកចិត្តទុកដាក់តែលើចំណុចដែលខ្លួនយល់ថា សំខាន់ ឬចំណុចគន្លឹះតែប៉ុណ្ណោះ។ ឧទាហរណ៍ចំពោះបញ្ហារបស់សាលាដូចជា ការកើនឡើងនូវអត្រាត្រួតថ្នាក់ និងបោះបង់ការសិក្សារបស់សិស្ស ឬអវត្តមានច្រើនរបស់សិស្ស នាយកសាលាដែលជាអ្នកគ្រប់គ្រងតែងផ្ដោតទៅលើកត្តាមួយចំនួនដែលខ្លួនយល់ថា ជាមូលហេតុចម្បងនៃបញ្ហា គឺភាពក្រីក្ររបស់ប្រជាជន និងកង្វះការចូលរួមរបស់មាតាបិតាសិស្សជាមួយសាលារៀន។ ម្ល៉ោះហើយគេក៏ផ្ដោតដំណោះស្រាយតែលើបញ្ហាទាំងពីរ។ ជាលទ្ធផល បញ្ហានៅតែមិនដោះស្រាយ។ ប៉ុន្តែចំពោះអ្នកដឹកនាំវិញមុននឹងឈានដល់ការសម្រេចយកដំណោះស្រាយ គេពិនិត្យគ្រប់ជ្រុងជ្រោយនៃបញ្ហា គ្រប់កត្តាដែលមានផលប៉ះពាល់ដល់បញ្ហានេះ។ ពិតមែនហើយថា ភាពក្រីក្រ និងកង្វះការចូលរួមរបស់មាតាបិតាសិស្សជាកត្តាមួយដែលប៉ះពាល់ដល់គុណភាពអប់រំ ប៉ុន្តែក្រៅពីកត្តាទាំងពីរនៅមានកត្តាជាច្រើនទៀតមានចំណែកទទួលខុសត្រូវក្នុងបញ្ហាគុណភាពនេះដែរ ដូចជាវិធីសាស្ត្របង្រៀន បរិស្ថានសាលារៀន សម្ភារៈបម្រើការរៀន និងបង្រៀន។ល។ អ្នកដឹកនាំសាលាពិតជាមិនមាន

លទ្ធភាពច្រើនក្នុងការដោះស្រាយបញ្ហាភាពក្រីក្របានទេ ប៉ុន្តែក្រៅពីនេះគេនៅអាចធ្វើការងារច្រើនទៀតដូចជា កែលំអវិធីបង្រៀន និងរៀន បង្កើនធនធានបំរើការរៀន និងបង្រៀន កែលំអបរិស្ថានសាលារៀនឱ្យមានភាពទាក់ទាញ និងបំរើការរៀន ។ល ។ អ្នកដឹកនាំគិតទៅគ្រប់បញ្ហាបែបនេះ... ពិនិត្យគ្រប់ជ្រុងជ្រោយនៃបញ្ហា ។

## ៧. ដឹកនាំគឺចោទសួរចំពោះបទបញ្ជា ឯគ្រប់គ្រងគឺគោរពបទបញ្ជា

អ្នកគ្រប់គ្រងរមែងមើលឃើញបទបញ្ជាថាត្រឹមត្រូវ មិនអាចកែប្រែបាន ។ គាត់តែងលើកឡើងថា "គេបានសម្រេចពីលើមកហើយ ភារកិច្ចរបស់យើងគឺត្រូវតែគោរពនូវអ្វីដែលបានសម្រេចហើយនេះ" ។ អ្នកដឹកនាំតែងចោទសួរពីបទបញ្ជា ។ ការចោទសួរធ្វើឱ្យគេបានជជែកគ្នា និយាយពន្យល់គ្នាទៅវិញទៅមក ម្ល៉ោះហើយគេក៏បានយល់កាន់តែច្បាស់ចំពោះបទបញ្ជានោះ ។ ម្យ៉ាងទៀត ការចោទសួរក៏អាចជួយឱ្យមានការកែលំអ សម្របសម្រួលបទបញ្ជា ហើយក៏បង្កើតបាននូវភាពជាម្ចាស់ និងលើកកម្ពស់ការចូលរួមផង ។

## ៨. ដឹកនាំគឺធ្វើត្រូវការងារ ឯគ្រប់គ្រងគឺធ្វើការងារត្រូវ

ភាពខុសគ្នារវាងពាក្យថា ធ្វើត្រូវការងារ និងធ្វើការងារត្រូវ ស្ថិតនៅលើទំនាក់ទំនងរវាងប្រធាន និងវត្ថុ ។ ធ្វើត្រូវការងារ មានទំនាក់ទំនងទៅនឹងវត្ថុដែលជាសាលារៀន បានន័យថា ធ្វើការងារដែលល្អ ឬត្រូវទៅនឹងតម្រូវការរបស់សាលារៀន ។ នេះហើយគឺអ្វីដែលអ្នកដឹកនាំពូកែរមែងធ្វើ ។ ចំពោះពាក្យថា ធ្វើការងារត្រូវនោះគឺទាក់ទងដល់ប្រធានដែលជានាយកសាលា បានន័យថា គាត់ធ្វើកិច្ចការដែលគេដាក់ឱ្យធ្វើនោះបានត្រឹមត្រូវ ។ នាយកសាលាដែលផ្តោតការយកចិត្តទុកដាក់ជាសំខាន់ត្រឹមតែទៅលើការធ្វើឱ្យបានល្អនូវរាល់ការណែនាំពីថ្នាក់លើនោះគ្រាន់តែជាអ្នកគ្រប់គ្រងទេ ។

(នៅមានត)

លោក អ៊ុច សារិត
អនុប្រធានមន្ទីរអ.យ.ក. ខេត្តតាកែវ
មន្ត្រីចូលនិវត្តន៍

អាហារថ្មីចខ្សឹតសឹត ធ្វើស្រែខ្សឹតទឹក
ត្រឹក(១) ពលខ្សឹតបាយ សិស្សប្រាជ្ញខ្សឹតគ្រូ
ដេរពោលដំណាយ ពលជាខ្សឹតនាយ
ហ្វឹកហ្វឺនខះខំៗ

ច្បាប់រាជនេតិ

(១) ត្រឹក : ដាស់តឿនក្រើនរំឭក ។

# មូលភេទ អ_អ៊ (ត)

### ៣.២_ឥទ្ធិពលព្យញ្ជនៈលើស្រៈ

សញ្ញាស្រៈភ្ជាប់តួខ្មែរយើងមានតែមួយពួក។ ផ្ទុយទៅវិញ សូរស្រៈមានពីរពួក គឺសូរស្រៈពួក អ និងសូរស្រៈពួក អ៊ិ។ ហេតុនេះយើងពុំដឹងអានវាដូចម្តេចទេ កាលណាវានៅម្នាក់ឯងដាច់ពីព្យញ្ជនៈ។ ដើម្បីអានសញ្ញាស្រៈជាសូរពួក អ ឬពួក អ៊ិ យើងពឹងផ្អែកលើសញ្ញាព្យញ្ជនៈ។ ផ្ទុយពីស្រៈ ព្យញ្ជនៈខ្មែរយើងមានសូរតែមួយពួក តែមានសញ្ញាពីរពួក គឺសញ្ញាព្យញ្ជនៈពួក អ និងសញ្ញាព្យញ្ជនៈពួក អ៊ិ។ សញ្ញាព្យញ្ជនៈពួក អ កំនត់សូរស្រៈពួក អ។ សញ្ញាព្យញ្ជនៈពួក អ៊ិ កំនត់សូរស្រៈពួក អ៊ិ។ ឯព្យាង្គវិញមានពីរពួក គឺព្យាង្គពួក អ និងព្យាង្គពួក អ៊ិ ទៅតាមសញ្ញាព្យញ្ជនៈដើមព្យាង្គ។

ឧទាហរណ៍ : តា [ta:] និង ទា [ti:ə] ÷

- សញ្ញាព្យញ្ជនៈ "ត" និង"ទ" ទាំងពីរនេះជាគូរនឹងគ្នាគឺ "ត" ជាពួក អ ឯ"ទ" ជាពួក "អ៊ិ"។ តែ"ត" និង"ទ" កត់សូរតែមួយគឺ [ត] = [ទ] = [t] ។
- សញ្ញាស្រៈ "ា" មានតែមួយពួក។ ប៉ុន្តែវាកត់សូរពីរពួក

"ា" { កត់សូរ [a:] ជាពួក អ
     { កត់សូរ [i:ə] ជាពួក អ៊ិ

- សញ្ញាព្យាង្គ "តា" កត់សូរ [ta:] សូរព្យាង្គពួក អ ដោយសំអាងលើសញ្ញាព្យញ្ជនៈពួក អ "ត" នៅដើមព្យាង្គ។
- សញ្ញាព្យាង្គ "ទា" កត់សូរ [ti:ə] សូរព្យាង្គពួក អ៊ិ ដោយសំអាងលើសញ្ញាព្យញ្ជនៈពួក អ៊ិ "ទ" នៅដើមព្យាង្គ។

អំនាងបែបខាងលើសំអាងទៅលើបដិសំយោគវិធី ដែលបុព្វបុរសយើងប្រើប្រាស់ក្នុងការសរសេរ និងអានព្យាង្គក្នុងភាសាខ្មែរ ÷

| ពួក | សញ្ញា | សូរ |
|---|---|---|
| អ | ត + ា => តា | t + a: => ta: |
| អ៊ិ | ទ + ា => ទា | t + i:ə => ti:ə |
| | (បដិសំយោគវិធី) | |

ផ្ទុយទៅវិញ ភាសាបរទេសដូចជា បាលី-សំស្ក្រឹត ជាដើមប្រើតក្កវិធីក្នុងការសរសេរ និងអានព្យាង្គក្នុងពាក្យ។ ស្រៈបាលី-សំស្ក្រឹត ពុំអាចអានម្តងបែបនេះ ម្តងបែបនោះឡើយ។ ស្រៈ "ា" អានថា [a:] (អា) មួយមុខតែប៉ុណ្ណោះ។ ឯ "ត" និង"ទ" ជាសទ្ទពីរផ្សេងគ្នា ÷

| សន្ធិ | សញ្ញា | សូរ |
|---|---|---|
| ព្យញ្ជនៈពីរ | ត + ា => តា | t + ā => tā |
| ផ្សេងគ្នា | ទ + ា => ទា | d + ā => dā |
| | (តក្កវិធី) | |

**<u>កំណត់សំគាល់:</u>**

- សញ្ញាព្យញ្ជនៈដើមព្យាង្គសុទ្ធតែជាអ្នកកំនត់សូរស្រៈពួក អ និងពួក អ៊ លើកលែងតែស្រៈ "ូ ឿ ៀ" ដែលមិនពឹងផ្អែកលើការកំនត់សូរពីសញ្ញាព្យញ្ជនៈឡើយ ។
- សញ្ញាស្រៈកប់តួពុំមានរូបរាងទេ ។ សញ្ញាព្យញ្ជនៈដើមព្យាង្គណាគ្មានសញ្ញាស្រៈភ្ជាប់តួនៅជាមួយ សញ្ញាព្យញ្ជនៈដើមព្យាង្គនោះមានស្រៈកប់តួ ។ សូរស្រៈកប់តួ "អ" ឬ "អ៊" អាស្រ័យសញ្ញាព្យញ្ជនៈដើមព្យាង្គ "អ" ឬ "អ៊" ។

ឧទាហរណ៍ : ក្នុងពាក្យ "តប" សញ្ញាព្យញ្ជនៈ "ត" មានស្រៈកប់តួ "អ" នៅជាមួយ ឯក្នុងពាក្យ "ទម" សញ្ញាព្យញ្ជនៈ "ទ" មានស្រៈកប់តួ "អ៊" នៅជាមួយ ។

- សញ្ញាព្យញ្ជនៈប្រកបពុំមានស្រៈនៅជាមួយទេ វាពុំមែនជាអ្នកកំនត់ពួករបស់ស្រៈទេ ។

**៣.៣_ឥទ្ធិពលព្យញ្ជនៈលើព្យញ្ជនៈក្នុងសញ្ញាព្យញ្ជនៈផ្សំ**

សញ្ញាព្យញ្ជនៈខ្មែរយើង បើចែកតាមមូលភេទ មានពីរពួក គឺពួក អ និងពួក អ៊ ។ បើចែកតាមពួកខ្យល់មានសញ្ញាព្យញ្ជនៈពួកខ្យល់ស្ទះ ពួកខ្យល់ច្រមុះ និងពួកខ្យល់បង្ហូរ ហើយបើចែកតាមឥទ្ធិពលមូលភេទ សញ្ញាព្យញ្ជនៈខ្មែរយើងអាចចែកជា ពីរ ក្រុមគឺ :

- ក្រុម ១ គឺមានក្រុមខ្លាំងមានសញ្ញាព្យញ្ជនៈខ្យល់ស្ទះទាំងអស់ និងសញ្ញាព្យញ្ជនៈខ្យល់បង្ហូរត្រដុស "ស"
- ក្រុម ២ គឺក្រុមខ្សោយមានសញ្ញាព្យញ្ជនៈខ្យល់ច្រមុះទាំងអស់ (លើកលែងតែតួ "ណ") និងសញ្ញាព្យញ្ជនៈខ្យល់បង្ហូរទាំងអស់ (លើកលែងតែតួ "ឡ" និង "ស") ។

**<u>តារាងព្យញ្ជនៈទាំងពីរក្រុម</u>**

| ក្រុម ១ (ក្រុមខ្លាំង) | | | ក្រុម ២ (ក្រុមខ្សោយ) | | | | | |
|---|---|---|---|---|---|---|---|---|
| សូរ | សញ្ញា | | សូរ | សញ្ញា | | សូរ | សញ្ញា | |
| | អ | អ៊ | | អ | អ៊ | | អ | អ៊ |
| k | ក | គ | | | | | | |
| kh | ខ | ឃ | ŋ | ង៉ | ង | j | យ៉ | យ |
| c | ច | ជ | | | | | | |
| ch | ឆ | ឈ | □ | ញ | ញ៉ | r | រ៉ | រ |
| d | ដ | ឌ | | | | | | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| t | ត | ទ | | | | | | |
| th | ថ ឋ | ធ ឍ | n | ន៉ | ន | l | ល៉ | ល |
| b | ប | ប៊ | | | | | | |
| p | ប៉ | ព | | | | | | |
| ph | ផ | ភ | m | ម៉ | ម | v | វ៉ | វ |
| □ | អ | អ៊ | | | | | | |
| s | ស | ស៊ | | | | h | ហ | ហ៊ |

ក្នុងក្រុម ១ សញ្ញាព្យញ្ជនៈពួក អ និងពួក អ៊ មានរូបរាងខុសគ្នាស្រលះលើកលែងតែសញ្ញាព្យញ្ជនៈ "អ" និង "ស"។ ក្នុងក្រុម ២ សញ្ញាព្យញ្ជនៈពួក អ និងពួក អ៊ មានរូបរាងដូចគ្នាតែមួយ។ វាខុសគ្នាត្រង់ពួក អ មានសញ្ញាវណ្ណយុត្តិមូសិកទន្ត ( ៉ ) នៅពីខាងលើ លើកលែងតែ "ហ" ដែលមានរូបរាងជាពួក អ ស្រេច។ ឯសញ្ញាព្យញ្ជនៈពួក អ៊ ក្នុងក្រុម ២ ពុំត្រូវការត្រីសព្ទទេ ព្រោះវាជាពួក អ៊ ស្រេច លើកលែងតែសញ្ញាព្យញ្ជនៈ "ហ" មួយប៉ុននោះដែលប្រើត្រីសព្ទ ( ៊ )។

ក្នុងបណ្ដាសញ្ញាព្យញ្ជនៈទាំងពីរក្រុម យើងចែកជា :

- ក្រុម ១ ជាក្រុមខ្លាំង វាមានឥទ្ធិពលមូលភេទ លើក្រុម ២
- ក្រុម ២ ជាក្រុមខ្សោយ វាគ្មានឥទ្ធិពលមូលភេទ លើក្រុមដទៃ តែវាទទួលឥទ្ធិពលពីក្រុម១ ទៅវិញ។

ឥទ្ធិពលមូលភេទនេះមានប្រយោជន៍សំរាប់សរសេរពាក្យបង្កើតជា "ក្បួនឥទ្ធិពលមូលភេទ" ឬជា "ក្បួនប្រាប់ស្រះ" ឬ "ក្បួនទំនាញសូរ" សំរាប់ណែនាំការប្រើប្រាស់មូសិកទន្ត និងត្រីសព្ទ។ គឺជាវិធីសំរួលអក្សរខ្មែរមិនអោយមានសញ្ញាអក្សរគរលើគ្នាច្រើនជាន់តាមខ្សែបន្ទាត់ឈរ។ បើយើងមិនប្រើក្បួនឥទ្ធិពលមូលភេទ អ-អ៊ ទេ យើងត្រូវបន្ថែមសញ្ញាវណ្ណយុត្តិមួយជាន់ទៀត : ត្រ៊ូវ ត្រ៊ើយ ខ្ទ៊ីត...។

ដូចសញ្ញាព្យញ្ជនៈទោលដើមព្យាង្គដែរ សញ្ញាព្យញ្ជនៈផ្សំជាអ្នកកំនត់សូរពួក អ និងសូរពួក អ៊ របស់ស្រះ។ ហេតុនេះសញ្ញាទាំងពីរនៃព្យញ្ជនៈផ្សំត្រូវតែកំនត់ខ្លួនឯងជាពួក អ ឬពួក អ៊។ ដើម្បីសំរេចបែបនេះយើងត្រូវអនុវត្ត "ក្បួនប្រាប់ស្រះ" ដែលឈរលើឥទ្ធិពលមូលភេទជាគោលមូលដ្ឋាន។

(នៅមានត)

លោក សូ មុយឃៀង

# គណិតវិទ្យា

## ការដោះស្រាយចំណោទ (ត)

១.សមត្ថភាពផ្សេងៗសម្រាប់ដោះស្រាយចំណោទគណិតវិទ្យា

**១.១-សមត្ថភាពប្រើប្រាស់ពាក្យខាងភាសានិយាយ និងសរសេរ**

- ញែកដាច់ពីគ្នានូវអត្ថបទចំណោទ និងសំណុំព័ត៌មានដែលមិនមែនជាចំណោទ
- ស្រាវជ្រាវរក និងវិភាគព័ត៌មានផ្សេងៗ ដែលមានប្រយោជន៍ និងគ្មានប្រយោជន៍ ដើម្បីឆ្លើយនឹងសំណួរ
- រកឃើញទីតាំងនៃព័ត៌មានដែលខ្វះ និងបំពេញបន្ថែមព័ត៌មាន ឬបម្រាប់ដែលត្រូវការចាំបាច់សម្រាប់ដោះស្រាយរកចម្លើយ
- ចេះផ្គុំ ឬប្រមូលព័ត៌មានទាំងឡាយ ដែលគេបានបង្ហាញជាទម្រង់ផ្សេងៗ (តារាង, គំនូរ, អត្ថបទ, ក្រាប...)
- តាក់តែងសំណួរដែលខ្វះ ឬដែលគ្មានក្នុងប្រធានចំណោទ
- សង្ខេបខ្លឹមសារប្រធានចំណោទស្មុគស្មាញឱ្យមកជាប្រធានចំណោទងាយយល់
- តាក់តែងចម្លើយឱ្យត្រូវនឹងសំណួរដែលគេសួរ។

**១.២-សមត្ថភាពបកស្រាយអត្ថន័យទាំងមូលរបស់អត្ថបទចំណោទ**

- តាក់តែងប្រធានចំណោទតាមរយៈព័ត៌មានជាអក្សរ ជាលេខ ឬល្បះលេខ
- ចេះភ្ជាប់ប្រធានចំណោទដែលគ្មានសំណួរទៅនឹងសំណួរ ឬល្បះលេខដែលគេឱ្យ
- រកឃើញ :
  - សំណួរដែលមានចម្លើយនៅក្នុងអត្ថបទចំណោទ
  - សំណួរដែលទាក់ទងទៅនឹងអត្ថបទ ប៉ុន្តែគេពុំអាចឆ្លើយបាន ដោយខ្វះព័ត៌មាន។

**១.៣-សមត្ថភាពផ្សេងៗ**

- ចេះតាងស្ថានភាពចំណោទឡើងវិញដោយមិនភ្លេចពីអ្វីដែលគេត្រូវរក
- ចេះទុកពេលពិចារណា (គ្រប់គ្រងពេលវេលា) និងផ្លាស់ប្តូររបៀបដោះស្រាយទៅតាមការយល់ឃើញ
- ចេះរៀបចំ បង្កើត រក្សាទុកទម្រង់នៃការសាកល្បង និងចេះផ្តួចផ្តើមគំនិតបង្កើតសម្មតិកម្ម ដោយប្រើប្រាស់សម្ភារៈដែលមាន
- ចេះគូររូប និងគូសគំនូសតាង ដើម្បីចៀសវាងការភ័ន្តច្រឡំ និងរៀបចំវិធីដោះស្រាយមួយក្នុង

ក្រុមខ័ណ្ឌចំណោទស្រាវជ្រាវដែលគេពុំទាន់បានបង្ហាញវិធីដោះស្រាយ

- ចេះពន្យល់ពីអ្វីដែលគេបានធ្វើ ចេះបកស្រាយពីដំណោះស្រាយរបស់គេ
- ចេះប្រៀបធៀបលទ្ធផលរបស់ខ្លួនទៅនឹងលទ្ធផលអ្នកដទៃ
- ចេះអះអាងបញ្ជាក់ពីភាពប្រើការបាននៃដំណោះស្រាយមួយ ចេះផ្គូរផ្គងជាមួយនឹងភាពជាក់ស្ដែង ចេះផ្ទៀងផ្ទាត់ភាពត្រឹមត្រូវដែលអាចទទួលយកបាន
- ចេះវាយតម្លៃលទ្ធផលរបស់ខ្លួន និងអ្នកដទៃ ។

**១.៤-សមត្ថភាពគណិតវិទ្យា**

- យល់ថា ចំណោទនីមួយៗអាចមានចម្លើយមួយ ឬច្រើន ឬគ្មានចម្លើយ
- យល់ថា របៀបដោះស្រាយចំណោទអាចមានច្រើនយ៉ាង មិនមែនមានតែម្យ៉ាងនោះទេ
- ចេះទាញបង្ហាញព័ត៌មានថ្មី ដោយផ្ដើមចេញពីព័ត៌មានដែលមានស្រាប់
- ចេះកសាងការតាងប្រមាណវិធីចំណោទមួយដែលជាលទ្ធផលនៃការបកស្រាយមួយជាក់លាក់ (បកស្រាយតាមបែបគណិតវិទ្យា)
- ចេះជ្រើសរើសឧបករណ៍គណិតវិទ្យាយ៉ាងត្រឹមត្រូវ (ការគណនា, ការគូររូប...)
- ចេះធ្វើការគណនាបានត្រឹមត្រូវល្អ (បច្ចេកទេសធ្វើប្រមាណវិធី)
- ចេះតាក់តែងរបៀបឆ្លើយ ។

<u>សមត្ថភាពមូលដ្ឋានសម្រាប់ដោះស្រាយចំណោទគណិតវិទ្យា</u>




(នៅមានត)

លោកស្រី ប៊ុន សារ៉ែន

# ល្បែងប្ដូរសារ

**គោលបំណង** : បង្កើនការយល់ដឹងពីរបៀបរៀបពាក្យក្នុង ឃ្លា ល្បះ ឱ្យបានត្រឹមត្រូវទៅតាមអត្ថន័យសេចក្ដីតាមរយៈការប្រើអក្សរបំបាំងខ្លឹមសារសេចក្ដី។

សម្ភារៈ ល្បះពាក្យងាយ សុភាសិត គតិអប់រំផ្សេងៗ។

## <u>សេចក្ដីណែនាំពីរបៀបលេង</u>

- មុនដំបូងត្រូវសរសេរឃ្លា/ល្បះតាមធម្មតាសិន។ ឧទាហរណ៍ : "ចិត្តល្អមិនក្រយូរ"
- ដាក់រូបមន្តសម្រាប់រាប់ដក ឬស្រង់។ ឧទាហរណ៍ : ដក ៣ ស្រង់ ៣ បានសេចក្ដីថា ដក ៣ គឺយកឃ្លា "ចិត្តល្អមិនក្រយូរ" មករាប់ពីអក្សរខាងដើមទៅខាងចុង។ ឧទាហរណ៍ :
  - ចិ រាប់ ១, ត្ត រាប់ ២, ល្អ រាប់ ៣, យកអក្សរ "ល្អ" មកសរសេរខាងដើមឃ្លា គឺ "ល្អ"
  - រាប់បន្ត គឺ មិ រាប់ ១, ន រាប់ ២, ក្រ រាប់ ៣ យកអក្សរ "ក្រ" មកសរសេរបន្តទៀត គឺ បាន ល្អ ក្រ
  - រាប់បន្តទៀត គឺ យូ រាប់ ១, រ រាប់ ២, ចិរាប់ ៣ យកអក្សរ "ចិ" មកសរសេរបន្ត គឺបាន ល្អ ក្រ ចិ រួចបន្តរាប់រហូតអស់អក្សរក្នុងឃ្លា/ល្បះជាទីបញ្ចប់ គឺបាន : "ល្អ ក្រ ចិ មិ យូ ត្ត នរ"។
- សរសេរអក្សរ "ល្អ ក្រ ចិ មិ យូ ត្ត ន រ" ក្នុងលិខិត រួចផ្ញើទៅមិត្តសំឡាញ់ឱ្យអានលិខិតនេះ រួចផ្ញើលិខិតឆ្លើយតបជាចម្លើយមកវិញ។ ឧទាហរណ៍ :

> **ជូនចំពោះសំឡាញ់ ចណ្ណា**
>
> សូមសំឡាញ់ជួយរៀបអក្សរខាងក្រោមនេះឱ្យទៅជាឃ្លា/ល្បះ មានន័យគ្រប់គ្រាន់តាមធម្មតា។
>
> ស្រង់ ៣ = "ល្អ ក្រ ចិ មិ យូ ត្ត ន រ"។
>
> **ពីខ្ញុំ បូណា រៀននៅសាលាបឋមសិក្សាទួលថ្ម, សូមអរគុណ!**

***<u>កំណត់សំគាល់:</u>***

- អាចដាក់ជាលំហាត់ពីឃ្លា/ល្បះ ពេញលេញ (ចិត្តល្អ មិនក្រយូរ)ឱ្យរកជាអក្សរ (ល្អ ក្រ ចិ មិ យូ ត្ត ន រ) និងបញ្ច្រាសពីអក្សរ "ល្អ ក្រ ចិ មិ យូ ត្ត ន រ" ឱ្យរកឃ្លា/ល្បះពេញលេញ (ចិត្តល្អ មិនក្រយូ) បានដូចគ្នា តែត្រូវកំណត់ពាក្យ ថាៈ ដក ៣ នៅមុខឃ្លា/ល្បះ (ចិត្តល្អមិនក្រយូរ) ឬស្រង់ ៣ នៅមុខអក្សរ "ល្អ ក្រ ចិ មិ យូ ត្ត ន រ"។

- ក្នុងការរាប់អក្សរត្រូវរាប់ព្យញ្ជនៈ និងស្រៈនៅខាងមុខអក្សរដាច់ពីគ្នា (ឧ-េ ែ ៃ...) តែចំពោះស្រៈនៅពីលើ និងក្រោយអក្សរព្រមទាំងជើងរបស់ព្យញ្ជនៈ ត្រូវរាប់ជាមួយព្យញ្ជនៈនោះ (ឧ-ចិ មិ ត្ត ឈ្នះ...)។

- អាចដាក់រូបមន្តផ្សេងៗក្នុងដក និងស្រង់។ ឧទាហរណ៍ :
  - ដក ២ "ចេះមិនឈ្នះចង់" ឬស្រង់ ៤ "ចះ ន ច េ មិ ឈ្នះ ង់"
  - ស្រង់២ "ន េ ឈ្នះ ចះ ច មិ ង់" ឬដក៤ "ចេះមិនឈ្នះចង់" ឬប្រើរូបមន្តដក់ ៣ ស្រង់ ៥ ឬដក ៥ ស្រង់ ៣ វិញក៏បាន
  - ដក ៣ = "អំពើអាក្រក់ល្អ ជារបស់ខ្លួន" ឬស្រង់ ៥ ="ពី ក់ រ ខ្លូ េ ក្រ ជា ស់ អំ អា ល្អ ប ន"
  - ដក ៤ = "ខ្មាស់ ល្ងង់ ទើបចេះ" ឬស្រង់ ៧ = "ង់ េ ល្ង ប ស់ ទី ខ្មា េ ចះ"។

**លោក ឈួយ ម៉ូចស្រេង** ប្រធានការិ.រដ្ឋបាល អ.យ.ក. ខេត្តកំពង់ចាម

# គំនូរ

## វិធីបង្រៀនគំនូរ (ត)

### <u>សត្វចតុប្បាទស្រុក (គំនូរស្ទាបពិភាក)</u>

សត្វចតុប្បាទស្រុក : គោ ជ្រូក ពពែ

ខ្លួនគោមានរាងចតុកោណកែង ឯខ្លួនជ្រូកវិញ មានរាងជារង្វង់ពងក្រពើ។ ចំពោះសត្វទាំងនេះត្រូវប្រុងប្រយ័ត្តនៅលើសមាមាត្ររបស់ជើងធ្លៀបទៅនឹងដងខ្លួន ជើងជ្រូកខ្លី ជើងគោមធ្យម ឯជើងពពែវែង។




ក-គោ ខ-របៀបគូរគោជាវត្ត គ-ជ្រូក ឃ-របៀបគូរជ្រូកជាវត្ត ង-ពពែ ច-របៀបគូរពពែជាវត្ត

# សត្វចតុប្បាទព្រៃ (គំនូរស្វាបប៉ាកកា)




ក-សីង្ហ ខ-របៀបគូរសីង្ហជាវត្ត គ-ខ្លាឃ្មុំ ឃ-របៀបគូរខ្លាឃ្មុំជាវត្ត ង-ប្រើស ច-របៀបគូរប្រើសជាវត្ត

**សត្វចតុប្បាទព្រៃ** : យើងមិនអាចគូរបង្ហាញនូវសត្វចតុប្បាទព្រៃទាំងអស់បានឡើយ។ ការជ្រើសរើសនូវសត្វខ្លះមកគូរជាគំរូ ដើម្បីបង្ហាញវិធីវិភាគរករាងពៅ និងសមាមាត្រដែលជាលំហាត់មួយមានប្រយោជន៍ដល់គ្រូ និងសិស្សដូចជាការរិះរកវិធីគូរជាវត្តនូវសត្វខ្លះដូចជា សិង្ហ ខ្លាឃ្មុំ និងឈ្លូស។ លំហាត់រិះរកនេះ ត្រូវគូរដំបូងជាគំនូស គឺវិភាគដើម្បីជាឧទាហរណ៍នូវរបៀបគូរជើងដែលមានរាងពៅប្រហែល១គ្នា ពិតមែនតែជើងសត្វទាំងនោះមានលក្ខណៈប្លែកគ្នាខ្លះ១។ (នៅមានត)

លោក ជ៉ាំ ត្រា




# ជីវភាពថ្មីលើដីពាមជាំង

(បទពាក្យ ៧)

ខ្ញុំមានវាសនាកើតជាខ្មែរ ចាប់ក្នុងផ្ទៃម៉ែផែចំការ
កៅស៊ូពាមជាំងខ្លាំងរុក្ខា រស់ក្នុងព្រឹក្សាសែនសុខសាន្ត ។

ពាមជាំងឈ្មោះថ្មីលើដីចាស់ នេះតាមប្រសាសន៍ម៉ែន ស៊ីថាន
ថ្នល់ក្រាលកៅស៊ូដូចសួគ៌ឋាន ភ្លើងភ្លឺប្រៀបបានទីក្រុងថ្មី ។

សំណង់អាគារច្រើនស្មេកស្អះ តូចធំថ្មីចាស់ខ្ពស់វែងខ្លី
នេះជាចំណេងចងដៃស្រី ដែលខំឃ្មាតខ្មីប្រឹងធ្វើការ ។

ខំចុះ!ខំចុះ!កុំគិតអី បញ្ចេញថ្វីដៃឱ្យអស្ចារ្យ
ពេលកូនកើតមកបានសិក្សា ពេលឈឺកាលណាព្យាបាលជូន ។

ថ្លៃទឹកថ្លៃភ្លើងថ្លៃស្នាក់នៅ ក្រុមហ៊ុនជូនពៅជាជំនូន
រស់ក្នុងសង្គមដោយរលូន សន្សំប្រាក់ពូនទុកថ្ងៃក្រោយ ។

លោក ជួប ហួតហេង
គ្រូបង្រៀនអនុវិ.ព្រែកស្បូវ ខេត្តកំពង់ធំ

# ផលប៉ះពាល់នៃឥទ្ធិពលគ្រឿងញៀន

ខ្ញុំជាពលរដ្ឋខ្មែរមួយនាក់ សូមជួយបញ្ជាក់ពីហេតុផល
អំពីគ្រឿងញៀនដែលប៉ះពាល់ ឱ្យបានស្គាល់យល់ទាំងប្រុសស្រី ។

បំណងអប់រំដល់ពួកជន ដែលបានភ្លេចខ្លួនភ្លេចស្មារតី
បណ្ដោយជីវិតមានតម្លៃ ឱ្យជួបគ្រោះភ័យក្ដីអន្តរាយ ។

គ្រាន់ទុកជាទុនពិចារណា លើគ្រប់ខ្លឹមសារបានបរិយាយ
រៀបរាប់ជាកាព្យបែបសម្រាយ អានហើយកុំណាយជួយប្រឹក្សា ។

ពីព្រោះគ្រឿងញៀនជាមេរោគ របស់ស្មោគគ្រោកដ៏អស្ចារ្យ
បើសិនប្រើវាពិតមរណា គ្មានព្រហ្មទេព្ដាជួយបានឡើយ ។

ទោះជាប្រភេទឈ្មោះម៉ាកអ្វី តែហ៊ានលូកដៃពិតជាធ្លោយ
នាំទុក្ខដល់ខ្លួនមិនល្ហែល្ហើយ កូនក្មួយចៅអើយកុំលេងវា ។

គ្រឿងញៀនកើតមានសព្វកន្លែង នាំទុក្ខចំបែងក្នុងរដ្ឋា
តាំងពីទីក្រុងស្រែចំការ ពុកម៉ែយាយតាក៏ធ្លាប់ដឹង ។

គ្រឿងញៀនធ្វើឱ្យមនុស្សកោងកាច ប្រើប្រាស់អំណាចទាំងទទឹង
សាហាវដូចតោខ្លាអញ្ជឹង បើសិនអ្នកហ្នឹងញៀនវាខ្លាំង ។

គ្រឿងញៀនធ្វើឱ្យមនុស្សភ្លីភ្លើ ល្ងិតល្ងង់ល្ងីល្ងើខ្លាចភ្លេចភ្លាំង
ក ខ នមោពុទ្ធោធាំង អាចហ៊ានគតាំងនឹងមច្ចុរាជ ។

គ្រឿងញៀនធ្វើឱ្យមនុស្សឆោតល្ងង់ ហ៊ានស៊ីតម្រង់ដូចបិសាច
ហ៊ានហោះចូលភ្លើងដូចមមាច ឆេះស្លាបដាច់ដោចស្លាប់គ្មានន័យ ។

គ្រឿងញៀនធ្វើឱ្យមនុស្សអាក្រក់ ភ្នែកសស្លេកស្លក់ដូចអវចី
ព្រាយអសុរកាយងើបពីដី ខានស៊ីចំណីរាប់រយឆ្នាំ ។

គ្រឿងញៀនធ្វើឱ្យមនុស្សសាហាវ ចិត្តខឹងឆេវឆាវមើលបំណាំ
ពាក្យល្អមិនស្ដាប់មិនចងចាំ យល់ឃើញភក់ជ្រាំជាឋានសួគ៌ ។

គ្រឿងញៀនធ្វើឱ្យមនុស្សវង្វេង ចាស់ ឬក៏ក្មេងតម្រង់ផ្លូវ
ទៅរកផ្លូវខុសមិនសមគួរ ដឹងរស់មិនយូរក៏ធ្វើដែរ ។

គ្រឿងញៀនឱ្យមនុស្សរមិលគុណ មិនស្គាល់ទោសបុណ្យគុណឪម៉ែ
ប្រមាថគុណគ្រូដូចជាឆ្កែ ហ៊ានថាស្ដីជេរស្មើសត្វធាតុ ។

គ្រឿងញៀនធ្វើឱ្យមនុស្សឆ្កួត ស៊ីឃោមកំអួតដូចជាប្រេត

គម្រង់លាមកឱ្យតែឆ្អែត      រស់បានមួយភ្លែតក៏ព្រមដែរ ។

គ្រឿងញៀនធ្វើឱ្យមានជម្ងឺ      ខ្លោចផ្សារពើតឈឺទុក្ខឥតល្ហែ

ត្រាំត្រែងភ្លាំរីត្មានទំនេរ      ប្រៀបដូចជាគេចាក់រុកដោត ។

គ្រឿងញៀនធ្វើឱ្យមនុស្សស្គាំងស្គម      រាងកាយទ្រុឌទ្រោមភ្នែកក្រឡោត

ខ្លួនដូចស្បូវក្តបដើរទ្រេតទ្រោត      ទោះចង់ហក់លោតធ្វើមិនបាន ។

គ្រឿងញៀនធ្វើឱ្យមនុស្សស្លេកស្លាំង      ថមថយកម្លាំងពីក្នុងប្រាណ

ភ្នែកស្លក់ល្អក់ស្លឹងបាយមិនឃ្លាន      ជីវិតនៅមានតែដូចស្លាប់ ។

គ្រឿងញៀនធ្វើឱ្យខ្វះកម្លាំង      ចង់ទប់តតាំងច្បាំងចាក់កាប់

ជាមួយសត្រូវពិតជាយ៉ាប់      ដូចនាំឱ្យងាប់បង់អាសារ ។

គ្រឿងញៀនធ្វើឱ្យកើតទុក្ខព្រួយ      ព្រោះតែរឿងមួយមិនធម្មតា

ពិបាករកលុយទិញយ៉ាម៉ា      អាភៀនកញ្ឆាហេរ៉ូអ៊ីន ។

គ្រឿងញៀនបានធ្វើឱ្យមនុស្សហ៊ាន      បំពារបំពានមិនខ្លាចមីន

មិនខ្លាចក្តីស្លាប់អន្តរធាន      នៅពេលដែលឃ្លានអ្វីក៏ធ្វើ ។

គ្រឿងញៀនធ្វើឱ្យមនុស្សចេះលួច      ទោះធំឬតូចគ្រប់អន្លើ

របស់របរសព្វសារពើ      អង្គុយដេកដើរគិតរកល្បិច ។

គ្រឿងញៀនធ្វើឱ្យហ៊ានសម្លាប់      អារ-ក ចាក់កាប់វាយកម្ទេច

វះពោះខ្វេះភ្នែកជាន់ពន្លិច      ចិញ្ច្រាំឱ្យខ្ទេចបំបាត់ដាន ។

គ្រឿងញៀនធ្វើឱ្យមនុស្សចេះប្លន់      ជីវិតទារពន្ធឥតស្រាកស្រាន្ត

មិនថាម៉ែឪញាតិសន្តាន      គិតឱ្យតែបានដោះមួយគ្រា ។

គ្រឿងញៀនឱ្យសិស្សភ្លេចសាលា      លទ្ធផលសិក្សាមុខវិជ្ជា

ត្រូវតែថយចុះខុសធម្មតា      បើញៀននឹងវាពុលងុលងប់ ។

គ្រឿងញៀនកំពុងក្លាយជាក្តី      បារម្ភភិតភ័យ ដេពិភព

ឱ្យព្រួយព្រីព្រួចទាំងថ្ងៃយប់      ព្រោះអ្នកសេពគប់កាន់តែច្រើន ។

មានចាស់មានក្មេងមានជំទង់      ប្រុសស្រីរញ្ជង់កំពុងកើន

ចំនួនប្រើប្រាស់មានកំណើន      ឱ្យមនុស្សភ្លើតភ្លើនគ្រប់១គ្នា ។

(នៅមានត)

លោក ហាស់ ម៉ុចតៅរ៉ា

អធិការប.ថ.ស. មន្ទីរអ.យ.ក.

❧📖❧

# ធម៌ដាស់តឿនកូនចៅ

ធ្វើបុណ្យជូនម៉ែទាន់ខែភ្លឺ កុំចាំម្ដាយឈឺស្លាប់មរណា
ទើបនាំបងប្អូនមកវេរជា ដល់គុណរូបាអាត្មាគាត់ ។
ធ្វើបុណ្យដូច្នេះហៅខែល្ងឹត កាលនៅជីវិតមិនមានមាត់
ដល់ពេលស្លាប់ហើយទើបគិតគាត់ យកធាតុដាក់វត្តឱ្យស្ដាប់ធម៌ ។
កាលម្ដាយឪពុកពិសាបាន កូនចៅប៉ុន្មានមិនត្រេកអរ
ជូនបាយចំណីម្ហូបសម្ល មិនមានសាទរបូជាឡើយ ។
កូនអើយប្រាយប្រាប់ដាស់គំនិត ម្ដាយនៅជីវិតរស់នៅឡើយ
ត្រូវតែបូជាទុកឱ្យហើយ កុំឱ្យស្ដាយក្រោយខានបូជា ។
ព្រះតង់ធម្មាបើកូននឹក រាល់ថ្ងៃយប់ព្រឹកត្រូវពិចារណា
ដល់អ្នកមានគុណធំលើសមហា ដល់គុណរូបាអាត្មាគាត់ ។
ព្រោះម្ដាយឪពុកទុកជាព្រះ ស្ថិតនៅលើផ្ទះបុត្រសុទ្ធសាធ
ហេតុនេះកូនចៅកុំប្រមាថ គោរពតាមខ្នាតពុទ្ធដីកា ។

លោក **ឈិន ច័ន្ទថន**
គ្រូអនុវិ.ជីដុះ ខេត្តកំពង់ចាម

## លើកតម្កើងគ្រូ

(បទកាកគតិ)

គ្រូមានគុណធ្ងន់ វិសេសលើសលន់ ខ្ញុំសែនរលឹក
នឹកដល់គុណលោក ទាំងល្ងាចទាំងព្រឹក គុណល្អពន្លឹក
លើសិស្សទាំងឡាយ។

លោកគ្រូអ្នកគ្រូ សមជាគំរូ យើងខ្ញុំទាំងឡាយ
លោកខំបង្រៀន ឥតមានជិនណាយ ទោះលំបាកកាយ
ឥតណាយចិន្តា។

ទោះក្ដៅរងា ឥតមានរុញរា ជួយជាតិសាសនា
បណ្ដុះទំពាំង ឱ្យមានផ្លែផ្កា ជ្រោងជាតិសាសនា
ព្រះមហាក្សត្រខ្មែរ។

ដកស្រង់ចេញពី : សៀវភៅ "សីលធម៌ព្រះពុទ្ធសាសនា"
ការចេញផ្សាយរបស់ពុទ្ធិកបណ្ឌិតសភានៃសកលវិ.បញ្ញាសាស្ត្រកម្ពុជា



# រឿងព្រេងភ្នំបាណន់

នៅទិសនិរតីនៃក្រុងបាត់ដំបងមានភ្នំតូចៗមួយក្រុមដូចជា រឿងព្រេងភ្នំបាណន់ ភ្នំសំពៅ ភ្នំក្ដោង ភ្នំទ្រុងមាន់ ភ្នំទ្រុងទា មានប្រវត្តិទាក់ទងក្នុងរឿងព្រេងខ្មែរយើង ។

កាលបើយើងធ្វើដំណើរទៅតាមដងស្ទឹងសង្កែ ក្នុងស្រុកសង្កែ ខេត្តបាត់ដំបង យើងនឹងឃើញភ្នំមួយឈ្មោះភ្នំបាណន់ នៅខាងលិចស្ទឹង ខាងអាគ្នេយ៍ទីក្រុងបាត់ដំបង ចម្ងាយប្រហែលជាង១០គ.ម. ពីទីក្រុងនេះ ។ ភ្នំនេះជាភ្នំសក្ដិសិទ្ធិមួយសម្រាប់អ្នកស្រុកធ្វើពលិការបូជាតាំងពីបូរាណកាលមក ។

ប្រវត្តិនៃភ្នំនេះមានដូចតទៅ "កាលពីព្រេងនាយ មានសេដ្ឋីម្នាក់មានកូនស្រីមួយឈ្មោះនាងរំសាយសក់ នាងនោះចេះតែឈឺដោយជំងឺរាំងរៃរ៉ូវជាយូរឆ្នាំ ។ ក្រោយមកមានតាបសម្នាក់ឈ្មោះ តាគ្រាម បានទទួលមើលជំងឺនាងនោះ លុះត្រាបានសះស្បើយ ។ កាលបើជាហើយ មហាសេដ្ឋីជាឪពុកនាងក៏បានផ្សំផ្គុំឱ្យជាភរិយាតាបសនោះ ។ តាបសបង្ហាត់បង្រៀនឱ្យចេះមន្ត-អាគមផ្សេងៗជាច្រើនមុខ មានមន្តហៅខ្យល់ព្យុះជាដើម ។

តាបស និងភរិយារស់នៅក្នុងរូងភ្នំមួយហៅថា ព្រះទឹក ឬប្រទឹក តាមសម្ដីអ្នកស្រុក ។ រូងភ្នំនោះនៅខាងត្បូងភ្នំបាណន់សព្វថ្ងៃដែលកាលនោះភ្នំបាណន់គេហៅថា ភ្នំប្រាសាទ នៅឡើយ ។

ខាងក្រោយមក មានព្រះរាជបុត្រស្ដេចមួយអង្គព្រះនាម ចៅរាជកុល មកសុំរៀនមន្តវិជ្ជាផ្សេងៗពីតាគ្រាម ។ តាបសសុខចិត្តបង្ហាត់បង្រៀនព្រះរាជបុត្រនេះលុះត្រាចេះ ប៉ុន្តែហាមព្រះរាជកុមារមិនឱ្យមើលប្រពន្ធគាត់សោះ ព្រោះនាងរំសាយសក់រូបល្អណាស់ ។

កន្លងជាយូរខែក្រោយមក ពេលជួនជាតាបសមិននៅចៅរាជកុល ទៅលួចមើលប្រពន្ធគាត់ឃើញរូបនាងល្អឆើតក៏កើតសេចក្ដីប្រតិព័ទ្ធ លួចសាកសួរចិត្តនាង ។ នាងស្រឡាញ់ចៅរាជកុលដែរ ក៏ទទួលព្រម ។

ថ្ងៃមួយតាបសចូលទៅក្នុងព្រៃដើម្បីរកវត្ថុផ្សេងៗ ។ អ្នកទាំងពីរបានឱកាសល្អក៏នាំគ្នាជិះសំពៅរត់ចោលតាបសទៅ ។

កាលតាបសត្រឡប់មកពីព្រៃវិញ ពុំឃើញមានមនុស្សនៅក្នុងរូងភ្នំសោះ គាត់ក៏ដឹងថា ចៅរាជកុល និងភរិយាគាត់ពង្រត់គ្នា ។ គាត់តាមទៅដល់មាត់សមុទ្របានឃើញសំពៅចៅរាជកុល និងនាងរំសាយសក់ឃ្លាតឆ្ងាយដល់ទៅកណ្ដាលសមុទ្រទៅហើយ ។ ខឹងណាស់ តាបសសែកមន្តវិជ្ជាហៅខ្យល់ព្យុះដើម្បីបំផ្លាញសំពៅនៅកណ្ដាលសាគរ ។ ប៉ុន្តែដោយនាងរំសាយសក់ចេះមន្តវិជ្ជាដែរ ក៏ធ្វើឱ្យខ្យល់បក់ផាត់ខ្យល់កំណាចនោះផុតអស់ទៅ ។ តាបស ឈឺចិត្តខ្លាំងពេកក៏ដួលស្លាប់នៅឆ្នេរសមុទ្រនោះឯង ។

អ្នកទាំងពីរដឹងហេតុដូច្នោះ ក៏នាំគ្នាត្រឡប់សំពៅមកកាន់រូងភ្នំប្រទីកវិញ រួមសុខទុក្ខជាមួយគ្នា។ ខាងក្រោយមក ចៅរាជកុលនឹកចង់ត្រឡប់ទៅស្រុកវិញ ក៏លាប្រពន្ធ សន្យាថានឹងត្រឡប់មករកនាងរំសាយសក់វិញ ដើម្បីរៀបការធ្វើជាអនុ-មហេសី។ នាងប្រពន្ធដើមមានចិត្តប្រចណ្ឌ ខឹងណាស់ ក៏ប្រើក្រពើរបស់នាងឈ្មោះអាធន់ ឱ្យទៅឃាំងផ្លូវកុំឱ្យចៅរាជកុលទៅវិញបាន។ ឃើញក្រពើកល់ទូកដូច្នោះ ចៅរាជកុល ក៏បង្គាប់ឱ្យគេបោះមាន់ទាទាំងទ្រុងទៅឱ្យក្រពើនោះស៊ី តែក្រពើនោះនៅតែធ្វើឱ្យសំពៅនោះលិចបាត់ក្តោង។ ឃើញដូច្នោះនាងរំសាយសក់ដកស្មៀតសក់បោះទៅក្នុងសមុទ្របួងសួងសុំឱ្យទឹកនោះរីង។ ទឹកសមុទ្រក៏រីងស្ងួត សំពៅក៏ក្លាយទៅជាភ្នំសំពៅ ក្តោងទៅជាភ្នំក្តោង។ អាធន់ក្រពើទៅជាភ្នំក្រពើ។ ទ្រុងមាន់ទ្រុងទាទៅជាភ្នំទ្រុងមាន់ ទ្រុងទា។ ឯនាងរំសាយសក់ លុះក្រឡេកឃើញសំពៅប្តីរៀបលិច ក៏បន់ទេវតាដែលនៅរក្សាភ្នំប្រាសាទថា សូមឱ្យតែជួយប្តីខ្ញុំឱ្យរួចពីគ្រោះថ្នាក់ចុះ ខ្ញុំនឹងថ្វាយភ្នំនេះ។ ការបន់នោះក៏បានសម្រេចដូចសេចក្តីប្រាថ្នា។ ចាប់តាំងពីនាងបន់នោះមកគេហៅភ្នំប្រាសាទនោះថា ភ្នំបាណន់ វិញ។ កាលណាបើយើងចូលទៅក្នុងរូងភ្នំបាណន់ យើងនឹងឃើញរូងភ្នំនេះមានដំបូលខាងលើរាងកោង ដូចដំបូលទូក។ នៅជញ្ជាំងរូងនោះមានកន្លែងទឹកស្រក់មួយ មានតម្រងរាងដូចត្បាល់បុកអង្ករ ទំហំប្រហែលជាប៉ុនល្អី។ រូងភ្នំនោះមានទំហំប្រហែល ១២ម៉ែត្របួនជ្រុង ជញ្ជាំងថ្ម ពុំមានចម្លាក់អ្វីទេ ប៉ុន្តែនៅខាងត្បូងតម្រងទឹកក្បែរជញ្ជាំងមានព្រះពុទ្ធរូបបាក់បែកជាច្រើន។

ពន្លឺព្រះអាទិត្យចូលទៅបំភ្លឺក្នុងរូងភ្នំនោះ តាមប្រហោងមួយនៅពីលើដំបូល។ គេចូលទៅក្នុងរូងនោះតាមផ្លូវមួយតូចងងឹតសូន្យ។ បើគេចង់ចូលទៅក្នុងនោះ គេត្រូវអុជចន្លុះបំភ្លឺផ្លូវ ហើយត្រូវដើរជាជួរបន្តគ្នាទើបអាចចូលទៅដល់កន្លែងទឹកស្រក់នោះបាន។

តាមអ្នកស្រុកភ្នំបាណន់នោះនិយាយថា ជួនកាលតម្រងទឹកនោះមានទឹកពេញ ជួនកាលមានទឹកតែត្រឹមពាក់កណ្តាលទេ គេថាបើតម្រងទឹកថ្មនោះមានទឹកពេញ ជាប្រផ្នូលឱ្យអ្នកស្រុកបានផលស្រូវបរិបូណ៌ បើទឹកកន្លះអ្នកស្រុកធ្វើស្រែពុំសូវបានផលទេ។

ទឹកដែលឃើញនៅតម្រងនោះថ្លាឆ្វង់ ហើយជនទាំងឡាយដែលទៅដល់ទីនោះមិនដែលខានក្បង់ទឹកនោះមកលុបលាងក្បាលទេ ដើម្បីសុំសេចក្តីសុខសប្បាយ។

រាល់តែឆ្នាំគេតែងធ្វើពិធីបូជានៅភ្នំបាណន់នេះ។ ចំពោះពេលចូលឆ្នាំថ្មី គេធ្វើខាងលើភ្នំនូវពិធីបុណ្យទាំងឡាយ មានពិធីពូនភ្នំខ្សាច់ និងនិមន្តលោកឆាន់ជាដើម ហើយមានរបាំ ប្រដាល់ និងមានចែកទានជាប្រាក់ ឬសម្លៀកបំពាក់ដល់អ្នកក្រផង។

នៅថ្ងៃទីមួយជាថ្ងៃចូលបុណ្យ គេតែងធ្វើពីធីបួងសួងសុំឱ្យទេវតាថ្មីជួយអ្នកស្រុកឱ្យបានសេចក្តីសុខសប្បាយ ហើយបើកាលណាគេភ្លេចធ្វើពិធីបួងសួងនេះមុខជាមានភ្លៀងធ្លាក់នៅពេលចូលឆ្នាំពាក់ថ្ងៃ ហើយអ្នកស្រុកនឹងកើតជំងឺពេញទាំងភូមិ។

ពិធីបួងសួងនោះមានស្វាធមិ បាយសី ហើយភ្លេងលេងបទបួងសួង។ តាមអ្នកស្រុកនិយាយថា កាលពីដើមតែកាលណាភ្លេងលេងបទបួងសួង គេមើលទៅក្នុងស្រះតាសែន ដែលនៅជិតជើងភ្នំបាណន់នោះ ឃើញក្រពើងើបជាច្រើន។ ស្រះនោះពីដើមជ្រៅ ប៉ុន្តែឥឡូវនេះរាក់ទេ ហើយនៅពេលបួងសួង គេក៏មិនឃើញក្រពើងើបទៀតឡើយ។

ពិធីនោះ ជួនកាលអ្នករាជការធ្វើ ជួនកាលអ្នកស្រុកនាំគ្នាធ្វើ។

លោក ចែម ផាន

សាស្ត្រាចារ្យប្រវត្តិវិទ្យា

# ប្រវត្តិកប៉ាល់ថ្ម

**រឿងនិទានបរទេស**

នៅមាត់ទន្លេបាតង់អូរ៉ ខាងកើតកោះស៊ូម៉ាត្រា មានដុំថ្មមួយយ៉ាងធំមានរាងដូចជាកប៉ាល់។ តើអ្នកដឹងទេថា ហេតុអ្វីបានជាមានដុំថ្មនោះ?

ជាយូរលង់មកហើយ មានអ្នកនេសាទត្រីម្នាក់រស់នៅតាមដងទន្លេបាតង់អូរ៉។ គាត់មានកូនជាច្រើននាក់ ប៉ុន្តែក្នុងនោះមានកូនប្រុសតែម្នាក់គត់។ គាត់មានគំនិតបញ្ជូនកូនប្រុសនោះឱ្យទៅរៀនយកចំណេះដឹងជ្រៅជ្រះក្នុងគោលដៅឱ្យកូនប្រុសគាត់មានអនាគតល្អ មានបុណ្យសក្តិ និងកិត្តិយស។

នៅពេលដែលកូនគាត់សិក្សាចប់ គាត់ក៏បានរកមុខរបរឱ្យកូនគាត់ធ្វើជាអ្នកជើរកប៉ាល់ក្រៅប្រទេស។ តាំងពីពេលនោះមក អ្នកនេសាទបានបែកកូនប្រុសគាត់ជាច្រើនឆ្នាំ។ ប៉ុន្តែគាត់បានដំណឹងថា កូនគាត់ជាមនុស្សឈ្លាសវៃខិតខំព្យាយាមធ្វើការងារឥតឈប់ឈរ។ គាត់មានក្តីសង្ឃឹមថា កូនគាត់នឹងក្លាយទៅជាមេបញ្ជាការនាវាម្នាក់ក្នុងថ្ងៃអនាគត។

ថ្ងៃខែចេះតែកន្លងទៅ កូនស្រីរបស់អ្នកនេសាទក៏បានរៀបការ ហើយចេញទៅរស់នៅតាមស្វាមីរៀង១ខ្លួន។ អ្នកនេសាទមានជំងឺជរាពាធ រួចក៏ទទួលមរណភាព ទុកឱ្យប្រពន្ធគាត់រស់នៅចិញ្ចឹមជីវិតដោយខ្លួនឯង។

ថ្ងៃមួយ អ្នកជិតខាងពីរនាក់ដើរយ៉ាងលឿននិយាយប្រាប់ប្រពន្ធអ្នកនេសាទថា :

-បងស្រីអើយ ! ខ្ញុំឃើញកូនប្រុសបងស្រីត្រឡប់មកវិញហើយ។

-ខ្ញុំមិនជឿពួកឯងទេ...។ គាត់ឆ្លើយ។

-ពិតមែនណាបងស្រី! អ្នកទីពីរនិយាយ។ កូនបងជាមេបញ្ជាការកប៉ាល់ផង គឺកប៉ាល់មកពីប្រទេសសិង្ហបុរី ដែលទើបចូលចតនៅកំពង់ផែយើងនេះ។ បងស្រីអញ្ជើញទៅមើលផ្ទាល់ភ្នែកចុះ។

ប្រពន្ធអ្នកនេសាទព្ញូដូច្នោះ ក៏ប្រញាប់ចំអិនម្ហូបដែលកូនប្រុសគាត់ចូលចិត្តជាងគេកាលពីនៅវ័យកុមារ រួចវេចខ្ចប់យកទៅផ្ញើកូន ដោយជ្រើសរើសខោអាវថ្មី១មកស្លៀកពាក់។ គាត់ជួលកូនទូកមួយជិះឆ្លងទៅកាន់កប៉ាល់ធំ ដែលបោះយុថ្កានៅកំពង់ផែ។

គាត់ឃើញបុរសម្នាក់យ៉ាងសង្ហា ឈរនៅជាន់នាវាខាងលើ។ "អូ! ពិតជាកូនប្រុសខ្ញុំហើយ!។ គាត់លាន់មាត់ដោយត្រេកអរ"។

-កូនប្រុសម្តាយ! គាត់ស្រែកហៅកូន។ ឯងមើលម៉ែមិនស្គាល់ទេឬ? ទឹកភ្នែកគាត់ក៏ហូរចេញដោយក្តីរំភើប។

-យាយជានរណា? កូនប្រុសឆ្លើយតប។ ខ្ញុំមិនដែលស្គាល់យាយឯងទេ! នែពួកឯង កុំឱ្យយាយនេះឡើងមកលើកប៉ាល់!។ កូនប្រុសគាត់បញ្ជាទៅនាវិកក្រោមបង្គាប់។

ថ្ងៃបន្ទាប់មក យាយជាម្តាយមករកកូនដល់កប៉ាល់ម្តងទៀត។ កូនគាត់នៅតែមិនឱ្យជួបមុខ។ ថ្ងៃទីបី នៅពេល

ក្រឡេកឃើញម្តាយមកដល់ កូនគាត់ក៏បញ្ជាឱ្យនាវិកដេញម្តាយឱ្យទៅឆ្ងាយពីកប៉ាល់ រួចនិយាយឱ្យម្តាយថា:

-ហេតុអ្វីបានជាយាយចាស់ឯងចេះតែមកកប៉ាល់អញ? ។ បើចង់សុំទានអញៗឱ្យបានពីរបីកាក់ តែអញមិនចូលចិត្តឱ្យយាយឯងថាខ្លួនជាម្តាយរបស់អញទេ! ។ ម្តាយឮហើយក៏ពោលដោយក្តីឈឺចាប់ថា :

-ល្អហើយកូនប្រុស! ព្រះជាម្ចាស់ពិតជាដាក់ទណ្ឌកម្មឯងនូវអំពើដ៏អាក្រក់នេះ។ ហេតុដូចម្តេចបានជាឯងហ៊ានបដិសេធពុំព្រមទទួលស្គាល់ម្តាយបង្កើតរបស់ខ្លួន? គាត់សំឡឹងមុខកូនប្រុសគាត់យ៉ាងយូរ ។ ប៉ុន្តែកូនប្រុសគាត់ងាកមុខចេញនៅស្ងៀមធ្វើហី ។

រំពេចនោះ ស្រាប់តែមានដុំពពកខ្មៅមួយយ៉ាងធំ រសាត់មកបាំងព្រះអាទិត្យ ធ្វើឱ្យងងឹតដូចយប់ ។ សន្ទឹកខ្យល់ព្យុះឮសូរគួរឱ្យខ្លាច រលកសមុទ្របោកបក់គ្រាំងៗទៅលើកប៉ាល់ ធ្វើឱ្យកប៉ាល់ប៉ះខ្ទប់នឹងផ្ទាំងថ្មឥតឈប់ឈរ ។ បង្គោលក្តោងរញ្ជួយបាក់ធ្លាក់ចុះ ហើយកប៉ាល់ក៏របូតយុថ្កា វិលចុះវិលឡើង រួចបែកលិចចុះទៅក្នុងសមុទ្រ ។ បន្ទាប់មក មានភ្លៀងធ្លាក់ខ្លោកៗងងឹតមេឃ ។

ក្រោយពេលដែលព្យុះភ្លៀងបានបញ្ចប់ទៅ ប្រពន្ធអ្នកនេសាទបានសំឡឹងមើលទៅកប៉ាល់កូនគាត់ម្តងទៀតជាចុងក្រោយ ។ គាត់គ្មានឃើញអ្វីក្រៅពីដុំថ្មមួយផ្ទាំងរាងដូចកប៉ាល់ លេចចេញពីក្នុងទឹកឡើយ ។

សម្រួល : លោកស្រី ហួរ សិរី

## រលកផ្ទប់ច្រាំង

(មេពាក្យ ៤)

កិច្ចស្ទួខ្ទម កុំស្ទួចខឹង ប្រឹងខាំមាត់
ហើយសង្កេត ហេតុសង្កត់ អត់ទោសា
ខុសប៉ុណ្ណឹង ខឹងប៉ុណ្ណោះ ចេះតែថា
សូមមើលការ សារមើលកាល ស្រាលឬធ្ងន់ ៗ
ខឹងហួសខ្លាត ខាតហួសខ្លាច ដាច់ដោយគ្នា
ខិលមកជា ខាមកជាប់ រាប់ដូចមុន
កាត់មិនដាច់ កាច់មិនដឹង ខឹងសិយស៊ុន
គិតកាលមុន គុណកាលមាន រៀនអំណត់ ៗ

អៀង សាយ




# តើលោកគ្រូ អ្នកគ្រូដឹងឬទេ...

- ភពផែនដីយើងនេះ បានកកើតឡើងតាំងពី ៤ពាន់៥រយលានឆ្នាំមកម្ល៉េះ (៤ ៥00 000 000ឆ្នាំ) ។
- ទម្រង់ជីវិតដំបូងៗ កើតមាននៅលើផែនដី តាំងពីអំឡុង ៣ពាន់៥រយលានឆ្នាំមុននេះ (៣ ៥00 000 000 ឆ្នាំ) ។
- ព្រះអាទិត្យជាដុំភ្លើងធំមួយ ប្រៀបបានទៅនឹង "មណ្ឌលនុយក្លេអ៊ែរ" ដែលស្នូលមានកំដៅសែនខ្ពស់ គឺដល់ទៅ ១៥លានអង្សាសេ (១៥ 000 000 °C) ។
- ស្រទាប់ក្រៅរបស់ព្រះអាទិត្យ ដែលបញ្ចេញកម្ដៅទៅកាន់ភពទាំងឡាយក្នុងចក្រវាឡ មានសីតុណ្ហភាពត្រឹមតែ ៤ ទៅ ៦ ពាន់អង្សាសេតែប៉ុណ្ណោះ (៤000-៦000°C) ។
- ដោយបានទទួលកម្ដៅពីព្រះអាទិត្យ ផែនដីរបស់យើងមានសីតុណ្ហភាពជាមធ្យម ១៥ អង្សាសេ (១៥°C) ។
